រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងកិច្ចការនារី (MOWA)

# គម្រោងបញ្ជ្រាបយេនឌ័រ
# ដើម្បីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី
# (PGM-WEE)

# របាយការណ៍បញ្ចប់គម្រោង

**ខែមករា ឆ្នាំ២០២៣**

**ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)**

**ក្រុមហ៊ុន IC Net Limited**

**មជ្ឈមណ្ឌលអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសជប៉ុន**

| |
|---|
| GP |
| JR |
| 23-003 |

# ផែនទីប្រទេសកម្ពុជា




ប្រភព៖ របាយការណ៍ស្តីពីការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចនៅកម្ពុជា ឆ្នាំ២០១៩/២០ (២០២០) របស់វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ ព្រះរាជាណាចក្រកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ (កែសម្រួលដោយគម្រោង PGM-WEE)

អត្រាប្តូរប្រាក់ គិតត្រឹមខែធ្នូ ឆ្នាំ២០២២
(ដុល្លារ) US Dollar (US$) 1 = 0 138.482000 (ប្រាក់យ៉េនជប៉ុន)
ប្រាក់រៀល (KHR) 1 = 0.026930 (ប្រាក់យ៉េនជប៉ុន)
(អត្រាប្តូរប្រាក់បរទេសរបស់ JICA ក្នុងខែធ្នូ ឆ្នាំ២០២២)

# តារាងមាតិកា

**I. ព័ត៌មានមូលដ្ឋានអំពីគម្រោង** 1
១.១. ប្រទេស៖ កម្ពុជា 1
១.២. ឈ្មោះគម្រោង 1
១.៣. រយៈពេលអនុវត្តគម្រោង (ផែនការដែលបានគ្រោង និងជាក់ស្តែង)៖ 1
១.៤. សារតា (ដកស្រង់ពីឯកសារកំណត់ត្រាកិច្ចពិភាក្សា(R/D)) 1
១.៥. គោលដៅរួម និងគោលបំណងគម្រោង (ដកស្រង់ពីឯកសារកំណត់ត្រាកិច្ចពិភាក្សា (R/D)) 2
១.៦. ភ្នាក់ងារអនុវត្តគម្រោង 2

**II. លទ្ធផលគម្រោង** 2
២.១. លទ្ធផលគម្រោង 2
២.១.១ ធាតុចូលខាងភាគីជប៉ុន (ផែនការដែលបានគ្រោង និងជាក់ស្តែង) 2
២.១.២ ធាតុចូលខាងភាគីកម្ពុជា (ផែនការដែលបានគ្រោង និងជាក់ស្តែង) 3
២.១.៣ សកម្មភាព (ផែនការដែលបានគ្រោង និងជាក់ស្តែង) 4
២.២. សមិទ្ធិផលរបស់គម្រោង 8
២.២.១. លទ្ធផល និងសូចនាករ 8
២.២.២. គោលបំណងគម្រោង និងសូចនាករ 10
២.៣. ប្រវត្តិ និងការកែសម្រួលតារាងម៉ាទ្រិករៀបចំគម្រោង (PDM) 13
២.៣.១. ខែមករា ឆ្នាំ២០២០ (សូមមើល ឧបសម្ព័ន្ធទី ៣-២) 13
២.៣.២. ខែមករា ឆ្នាំ២០២២ (សូមមើល ឧបសម្ព័ន្ធទី ៣-៣) 19
២.៤. ផ្សេងៗ 20

**III. លទ្ធផលនៃការត្រួតពិនិត្យរួមគ្នា** 20
៣.១. លទ្ធផលនៃការត្រួតពិនិត្យដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ **DAC** នៃការវាយតម្លៃ 20
៣.១.១. ភាពពាក់ព័ន្ធ៖ ខ្ពស់ 20
៣.១.២. ការផ្សារភ្ជាប់៖ ខ្ពស់ 22
៣.១.៣. ប្រសិទ្ធភាព៖ ខ្ពស់បង្គួរ 22
៣.១.៤. ប្រសិទ្ធផល៖ មធ្យម 24
៣.១.៥. ផលប៉ះពាល់៖ កម្រិតមធ្យម 24
៣.១.៦. និរន្តរភាព៖ មធ្យម 25
៣.២. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ការអនុវត្ត និងលទ្ធផលគម្រោង 25
៣.៣. លទ្ធផលនៃការវាយតម្លៃទៅលើការគ្រប់គ្រងហានិភ័យគម្រោង 26
៣.៤. មេរៀន និងបទពិសោធន៍ដែលទទួលបាន 26

៣.៥. សកម្មភាពបន្ថែម/សកម្មភាពគាំទ្រដែលចាំបាច់
ក្នុងការឆ្លើយតបទៅនឹងកូវីដ-១៩ ........ 27
**IV. ការសម្រេចបាននូវគោលដៅរួមបន្ទាប់ពីគម្រោងបញ្ចប់** ........ 27
៤.១. លទ្ធផលរំពឹងទុកក្នុងការសម្រេចបានគោលដៅរួម ........ 27
៤.២. ផែនការប្រតិបត្តិ និងរចនាសម្ព័ន្ធអនុវត្តការងាររបស់ភាគីកម្ពុជាដើម្បីសម្រេចបាននូវ
គោលដៅរួមរបស់គម្រោង ........ 28
៤.៣. អនុសាសន៍សម្រាប់ភាគីកម្ពុជា........ 29
៤.៤. ផែនការតាមដានត្រួតពិនិត្យបន្ទាប់ពីគម្រោងបញ្ចប់
រហូតដល់ពេលធ្វើការវាយតម្លៃ ........ 30

តារាងឧបសម្ព័ន្ធ៖
១. លទ្ធផលរបស់គម្រោង
២. បញ្ជីឯកសារ
៣. តារាងម៉ាទ្រិករៀបចំគម្រោង (PDM)
៤. កំណត់ត្រាកិច្ចពិភាក្សា(RD) និងកំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរួម (MM, Minute of JCC)
៥. ឯកសារនៃការត្រួតពិនិត្យ

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AIMS | គម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| ASPIRE | កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ |
| EDD | នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច |
| GBV | អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ |
| GED | នាយកដ្ឋានសមភាពយេនឌ័រ |
| GMAG | ក្រុមការងារបញ្ជ្រាបយេនឌ័រ |
| GMAP | ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ |
| H.E. | លោកជំទាវ ឬ ឯកឧត្តម |
| IFAD | មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍន៍កសិកម្ម |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន |
| KCH | ខេត្តកំពង់ឆ្នាំង |
| KPC | ខេត្តកំពង់ចាម |
| KPT | ខេត្តកំពង់ធំ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MISTI | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| MOC | ក្រសួងពាណិជ្ជកម្ម |
| MOLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MORD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| MOT | ក្រសួងទេសចរណ៍ |
| MOU | ការចុះអនុស្សរណៈនៃការយោគយល់គ្នា |
| MOWA | ក្រសួងកិច្ចការនារី |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| OVOP | ភូមិមួយផលិតផលមួយ |
| PDISTI | មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| PDWA | មន្ទីរកិច្ចការនារី |
| PGM | គម្រោងបញ្ជ្រាបយេនឌ័រ |
| PGM-WEE | គម្រោងបញ្ជ្រាបយេនឌ័រដើម្បីលើកកម្ពស់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី |
| PSD | នាយកដ្ឋានផែនការ និងស្ថិតិ |
| R/D | កំណត់ត្រាកិច្ចពិភាក្សា |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SRP | ខេត្តសៀមរាប |
| TBK | ខេត្តត្បូងឃ្មុំ |
| TWG-G | ក្រុមការងារបច្ចេកទេសយេនឌ័រ |
| TWG-G WEE | ក្រុមការងារបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៃក្រុមការងារបច្ចេកទេសយេនឌ័រ |
| WCCC | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| WEE | ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី |
| WEE-WG | ក្រុមការងារបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី |

# របាយការណ៍បញ្ចប់គម្រោង (ពង្រាង)

ឈ្មោះគម្រោង៖ <u>គម្រោងស្តីពីការបញ្ជ្រាបយេនឌ័រដើម្បីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (PGM-WEE)</u>

**ឈ្មោះ** លោកជំទាវ ច័ន្ទ សូរិយ៍
**តួនាទី៖** រដ្ឋលេខាធិការ និងជានាយកគម្រោង
**ឈ្មោះ៖** លោកស្រី អាកាណេ តូតានី (Akane Totani)
**តួនាទី៖** ប្រធានទីប្រឹក្សាគម្រោង
**កាលបរិច្ឆេទប្រគល់៖** ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២

## I. ព័ត៌មានមូលដ្ឋានអំពីគម្រោង

១.១. ប្រទេស៖ កម្ពុជា

១.២. ឈ្មោះគម្រោង៖

គម្រោងស្តីពីការបញ្ជ្រាបយេនឌ័រដើម្បីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (PGM-WEE)

១.៣. រយៈពេលអនុវត្តគម្រោង (ផែនការដែលបានគ្រោង និងជាក់ស្តែង)៖

ពេលវេលាដែលបានគ្រោង ៖ ខែកុម្ភៈ ឆ្នាំ២០១៧ – ខែកុម្ភៈ ឆ្នាំ២០២២ (រយៈពេល៥ ឆ្នាំ)
ពេលវេលាជាក់ស្តែង៖ ខែកុម្ភៈ ឆ្នាំ២០១៧ – ខែធ្នូ ឆ្នាំ២០២២ (រយៈពេល ៥ឆ្នាំ ១០ខែ)

១.៤. សាវតា (ដកស្រង់ពីឯកសារកំណត់ត្រាកិច្ចពិភាក្សា(R/D))

រាជរដ្ឋាភិបាលកម្ពុជា (RGC) បានអនុវត្តកម្មវិធី និងគម្រោងជាច្រើន សម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី ដោយផ្អែកលើគោលនយោបាយជាតិ ដូចជាយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងនារីរតនៈ (ដែលជាផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំរបស់ក្រសួងកិច្ចការនារី (MOWA))។ ដោយផ្អែកលើកិច្ចសហប្រតិបត្តិការរយៈពេលវែងរវាងក្រសួងកិច្ចការនារី (MOWA) និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ចាប់តាំងពីដើមទសវត្សរ៍ ឆ្នាំ ១៩៩០ គម្រោង ចំនួនពីរត្រូវបានអនុវត្ត គឺគម្រោងស្តីពីការបញ្ជ្រាបយេនឌ័រ (PGM) ដំណាក់កាលទី១ និងទី២។ គម្រោងPGM 2 បានចាប់ផ្តើមឡើងក្នុងឆ្នាំ២០១០ សម្រាប់រយៈពេល៥ឆ្នាំ ជាមួយនឹងគោលដៅរួមគឺការលើកកម្ពស់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (WEE) ត្រូវបានពង្រឹងតាមរយៈគោលនយោបាយ និងកម្មវិធីដែលឆ្លើយតបនឹងយេនឌ័រ ដែលអនុវត្តដោយក្រសួងកិច្ចការនារី (MOWA) ឬ មន្ទីរកិច្ចការនារីខេត្ត (PDWA) និងក្រសួងដៃគូនានានៅក្នុងប្រទេសកម្ពុជា។

លទ្ធផលនៃការវាយតម្លៃ និងការសិក្សាអំពីគម្រោង PGM 2 ដែលបានអនុវត្តក្នុងខែកុម្ភៈ ឆ្នាំ២០១៥ បានសន្និដ្ឋានថាមុខងារ និងសមត្ថភាពរបស់ក្រសួង/មន្ទីរកិច្ចការនារីក្នុងការស្វែងរកការគាំទ្រមតិ ការសម្របសម្រួលជាមួយក្រសួង និងមន្ទីរពាក់ព័ន្ធដែលជាដៃគូនៅថ្នាក់ក្រោមជាតិត្រូវបានពង្រឹង។ ការសិក្សាក៏បានរកឃើញផងដែរថា ការផ្តល់សេវាឆ្លើយតបនឹងយេនឌ័រសម្រាប់ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅថ្នាក់ក្រោមជាតិតាមរយៈការអនុវត្តវិធីសាស្ត្រ PGM ដែលបានបង្កើតឡើងនៅក្នុងគម្រោង PGM1 និងអនុវត្តគម្រោងសាកល្បងនៅក្នុងខេត្តកំពង់ចាម។ លើសពីនេះទៅទៀត លទ្ធផលរបស់គម្រោង PGM2 បានបង្ហាញថា ផែនការវិនិយោគ ៣ឆ្នាំ រំកិលរបស់ខេត្តកំពង់ចាមភាគច្រើនបានរៀបចំឡើងមានការឆ្លើយតបនឹងយេនឌ័រ។

គួរកត់សម្គាល់បន្ថែមទៀតផងដែរថា គម្រោង PGM2 បានបង្កើតនូវលទ្ធផលក៏ដូចជាផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច-សង្គម

និងយេនឌ័រទៅលើអ្នកពាក់ព័ន្ធនៅកម្រិតថ្នាក់ខេត្តដូចខាងក្រោម៖

១). ការកើនឡើងនៃប្រាក់ចំណូលគ្រួសារ និងការលើកម្ពស់ជីវភាពរស់នៅរបស់ស្ត្រី និងបុរសដែលជាផលប៉ះពាល់បែបវិជ្ជមាននៅក្នុងផ្នែកសេដ្ឋកិច្ច។

២). ការកែលម្អទំនាក់ទំនងនៅក្នុងគ្រួសារ ការបង្កើតនូវសុខដុមរមនា ការកាត់បន្ថយអំពើហិង្សាផ្អែកលើ យេនឌ័រ (GBV) ការពង្រឹងភាពអង់អាចរបស់ស្ត្រី (ដូចជា៖ បង្កើនទំនុកចិត្តលើខ្លួនឯង ភាពជាអ្នកដឹកនាំ និងការចូលរួមធ្វើសេចក្តីសម្រេចចិត្តលើការចំណាយទិញរបស់ថ្លៃៗក្នុងគ្រួសារ) និងការលើកកម្ពស់ការយល់ដឹង និងទទួលស្គាល់សមត្ថភាពរបស់ស្ត្រីតាមរយៈសមាជិកគ្រួសារ និងសហគមន៍ដែលជាផលប៉ះពាល់វិជ្ជមាននៅក្នុងផ្នែកសង្គម និងយេនឌ័រ។

លទ្ធផលរបស់គម្រោង PGM2 ឃើញថាវិធីសាស្ត្រ PGM គឺជាឧបករណ៍ និងយន្តការសំខាន់ក្នុងការបញ្ជ្រាបយេនឌ័រនៅកម្ពុជា។ លើសពីនេះទៅទៀត វិធីសាស្ត្រដែលបានកែសម្រួលដោយ PGM2 បាន ជំរុញ និងលើកកម្ពស់ការបញ្ជ្រាបយេនឌ័រទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទៅតាមខ្សែបណ្តោយរបស់ក្រសួង/មន្ទីរពាក់ព័ន្ធ។ ស្របជាមួយគ្នានេះដែរ ក្នុងខែសីហា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជា បានស្នើសុំជំនួយបន្ថែមពីរាជរដ្ឋាភិបាលជប៉ុន ដើម្បីពង្រឹងយន្តការបញ្ជ្រាបយេនឌ័រដែលមានស្រាប់ និងពង្រីកបន្ថែមឱ្យកាន់តែទូលំទូលាយ។

១.៥. គោលដៅរួម និងគោលបំណងគម្រោង (ដកស្រង់ពីឯកសារកំណត់ត្រាកិច្ចពិភាក្សា(R/D))

**១) គោលដៅរួម (បានកែសម្រួលឡើងវិញក្នុងខែមករា ឆ្នាំ២០២០)**

ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (WEE) ត្រូវបានលើកកម្ពស់តាមរយៈកម្មវិធី និងគម្រោងឆ្លើយតបនឹងយេនឌ័រ ដែលបានអនុវត្តនៅថ្នាក់ក្រោមជាតិដោយក្រសួង/មន្ទីរពាក់ព័ន្ធ តាមរយៈការស្វែងរកការគាំទ្រមតិ និងការសម្របសម្រួលពីក្រសួង/មន្ទីរកិច្ចការនារី (MOWA/PDWA) នៅក្នុងខេត្តគោលដៅ និងខេត្តមិនមែនគោលដៅ។

**២) គោលបំណងគម្រោង**

យន្តការបញ្ជ្រាបយេនឌ័រត្រូវបានពង្រឹងដើម្បីលើកកម្ពស់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (WEE) នៅថ្នាក់ក្រោមជាតិ ដោយក្រសួង/មន្ទីរដៃគូពាក់ព័ន្ធ តាមរយៈការស្វែងរកការគាំទ្រមតិ និងការសម្របសម្រួលពីក្រសួង/មន្ទីរកិច្ចការនារី (MOWA/PDWA)។

១.៦. ភ្នាក់ងារអនុវត្តគម្រោង

ក្រសួងកិច្ចការនារី (MOWA)

II. លទ្ធផលរបស់គម្រោង

២.១. លទ្ធផលរបស់គម្រោង

២.១.១ ធាតុចូលខាងភាគីជប៉ុន (ផែនការដែលបានគ្រោង និងជាក់ស្តែង)

| **ផែនការដែលបានគ្រោងទុក**<br>**(ដកស្រង់ពីកំណត់ត្រាកិច្ចពិភាក្សា** R/D **ដើម)** | **ជាក់ស្តែង** |
|---|---|
| (1) **ការបញ្ជូនជំនាញការ**<br>- ប្រធានទីប្រឹក្សា / ជំនាញការផ្នែកបញ្ជ្រាបយេនឌ័រ<br>- ជំនាញការផ្នែកអភិវឌ្ឍន៍ស្ថាប័ន<br>- ជំនាញការផ្នែកបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី<br>- ជំនាញការសម្របសម្រួល / បណ្តុះបណ្តាល | (1) **ការបញ្ជូនជំនាញ**<br>(សូមមើលឧបសម្ព័ន្ធ ១-១)<br>- ប្រធានទីប្រឹក្សា / ផ្នែកបញ្ជ្រាបយេនឌ័រ ១(16.42PM)<br>- អនុប្រធានទីប្រឹក្សា / ផ្នែកបញ្ជ្រាបយេនឌ័រ ២ (8.98PM)<br>- ជំនាញការផ្នែកអភិវឌ្ឍន៍ស្ថាប័ន/អភិបា |

| | |
|---|---|
| - ជំនាញរយៈពេលខ្លីទៅតាមប្រធានបទជាក់លាក់<br>(2) **វគ្គបណ្តុះបណ្តាលក្រៅប្រទេស**<br>(3) **រថយន្ត គ្រឿងបរិក្ខា និងសម្ភារៈការិយាល័យ** | លកិច្ច (12.3PM)<br>- ជំនាញការផ្នែកបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (15.8PM)<br>- ជំនាញការផ្នែកអភិវឌ្ឍន៍ទីផ្សារ និងអាជីវកម្ម (14.58PM)<br>- ជំនាញការគ្រប់គ្រងវគ្គបណ្តុះបណ្តាល (1.2PM)<br>- ជំនាញការសម្របសម្រួល / ការវិភាគលទ្ធផល យេនឌ័រ (14.00PM)<br>- ជំនាញការតាមដានត្រួតពិនិត្យ (រយៈពេលខ្លី) (0.82PM)<br>(2) **វគ្គបណ្តុះបណ្តាលក្រៅប្រទេស៖** មិនមានវគ្គបណ្តុះបណ្តាល នៅប្រទេសជប៉ុនត្រូវបានផ្លាស់ប្តូរទៅជាសិក្ខាសាលាចែករំលែកបទពិសោធន៍ (retreat program) នៅក្នុងប្រទេសកម្ពុជា ដោយសារការរឹតបន្តឹងការធ្វើដំណើរ អំឡុងពេលកូវីដ-១៩។<br>(3) **រថយន្ត គ្រឿងបរិក្ខា និងសម្ភារៈការិយាល័យ**<br>(សូមមើលឧបសម្ព័ន្ធ ១-៥-១)<br>- ១.១ លានយ៉េនជប៉ុន<br>(4) **ចំណាយលើសកម្មភាពក្នុងស្រុក៖**<br>- ១៥៤.៩ លានយ៉េនជប៉ុន (តួលេខបណ្តោះអាសន្ន) |

២.១.២ ធាតុចូលខាងភាគីកម្ពុជា (ផែនការដែលបានគ្រោង និងជាក់ស្តែង)

| ផែនការដែលបានគ្រោងទុក<br>(ដកស្រង់ពីកំណត់ត្រាកិច្ចពិភាក្សា R/D ដើម) | **ជាក់ស្តែង** |
|---|---|
| **(1) ការចាត់តាំងមន្ត្រីដៃគូ និងផ្នែករដ្ឋបាល**<br>- នាយិកាគម្រោង៖ រដ្ឋលេខាធិការ MOWA<br>- ប្រធានគម្រោង៖ ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ (PSD)<br>- មន្ត្រី/សមាជិក៖ មន្ត្រីដៃគូមកពីនាយកដ្ឋានផែនការ និងស្ថិតិ (PSD) នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច (EDD) និងនាយកដ្ឋានសមភាពយេនឌ័រ (GED)<br><br>(2) **ការិយាល័យធ្វើការនៅ** MOWA **និង** PDWAs **នៃខេត្តគោលដៅ** | (1) **ការចាត់តាំងមន្ត្រីដៃគូ និងផ្នែករដ្ឋបាល** (សូមមើលឧបសម្ព័ន្ធ ១-៣)<br>- នាយិកាគម្រោង៖ រដ្ឋលេខាធិការ MOWA<br>- ប្រធានគម្រោង៖ ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ (PSD)<br>- មន្ត្រី/សមាជិក៖ មន្ត្រីដៃគូមកពីនាយកដ្ឋាន ផែនការនិងស្ថិតិ(PSD) នាយកដ្ឋានអភិវឌ្ឍន៍ សេដ្ឋកិច្ច(EDD) និងនាយកដ្ឋានសមភាព យេនឌ័រ (GED)<br>(2) **ការិយាល័យធ្វើការនៅ** MOWA **និង** PDWAs **នៅខេត្តកំពង់ឆ្នាំង និងសៀមរាប**<br>* ដោយសារការរឹតបន្តឹងការធ្វើដំណើរក្នុងអំឡុងពេលកូវីដ-១៩ គម្រោងមិនត្រូវការការិយាល័យធ្វើការនៅក្នុងខេត្តកំពង់ធំ និងខេត្តត្បូងឃ្មុំទេ ដោយសារសកម្មភាពសាកល្បងភាគច្រើនត្រូវបាន |

| | |
|---|---|
| | អនុវត្ត តាមប្រព័ន្ធអនឡាញ។ |

២.១.៣ សកម្មភាព (ផែនការដែលបានគ្រោង និងជាក់ស្តែង)

| **ផែនការដែលបានគ្រោងទុក (ដកស្រង់ពីកំណត់ត្រាកិច្ចពិភាក្សា R/D ដើម)** | **ជាក់ស្តែង** |
|---|---|
| **<លទ្ធផលរំពឹងទុកទី ១>** សមត្ថភាពរបស់ MOWA/PDWA ក្នុងការស្វែងរកការគាំទ្រមតិ និងការសម្របសម្រួល ត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (WEE) នៅថ្នាក់ក្រោមជាតិ។ | |
| 1.1. បានធ្វើការវាយតម្លៃសមត្ថភាពផ្នែកយេនឌ័រ។ | 1.1. បានធ្វើការវាយតម្លៃសមត្ថភាពផ្នែកយេនឌ័រនៅក្នុង ខែមករា ឆ្នាំ២០២០ និងខែកក្កដា ឆ្នាំ២០២២។ |
| 1.2. បានរៀបចំ "ផែនការកសាងសមត្ថភាពស្តីអំពី WEE" យោងតាមលទ្ធផលនៃការវាយតម្លៃ។ | 1.2. បានគ្រោង និងរៀបចំការអភិវឌ្ឍន៍សមត្ថភាពរបស់ MOWA និង PDWA ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃ។ |
| 1.3. បានគ្រោងរៀបចំ និងបើកវគ្គសិក្ខាសាលា និងវគ្គ បណ្តុះបណ្តាលជាបន្តបន្ទាប់ ដើម្បីពង្រឹងសមត្ថភាពរបស់ MOWA/PDWA ក្នុងការស្វែងរកការគាំទ្រមតិ និងការសម្របសម្រួល ដើម្បីលើកកម្ពស់ WEE។ | 1.3. បានរៀបបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់ (សូមមើលឧបសម្ព័ន្ធ១-៦)។ |
| 1.4. បានធ្វើបច្ចុប្បន្នភាព"សៀវភៅសន្ទានុក្រមយេនឌ័រ"។ | 1.4. សៀវភៅសន្ទានុក្រមយេនឌ័រត្រូវបានរៀបចំ និងអនុម័តដោយ MOWA នៅចុងខែវិច្ឆិកា ឆ្នាំ២០២២។ ទោះយ៉ាងណា សៀវភៅនេះនៅមិនទាន់បានអនុម័ត ឱ្យបោះពុម្ព និងផ្សព្វផ្សាយនៅចុងបញ្ចប់នៃគម្រោងនៅឡើយទេ។ សង្ឃឹមថា MOWA នឹងស្វែងរកប្រភពសម្រាប់បោះពុម្ពបន្ទាប់ពីទទួលបានការអនុម័ត។ |
| 1.5. បានធ្វើបច្ចុប្បន្នភាព "ខិត្តប័ណ្ណស្ថិតិយេនឌ័រ"។ | 1.5. ខិត្តប័ណ្ណស្ថិតិយេនឌ័របានធ្វើបច្ចុប្បន្នភាព និងចែកចាយជាផ្លូវការ។ |
| 1.6. បានរៀបចំ និងចងក្រង "សៀវភៅស្ថិតិយេនឌ័រប្រចាំខេត្ត" សម្រាប់ខេត្តគោលដៅនីមួយៗ។ | 1.6. បានរៀបចំ និងចងក្រងសៀវភៅស្ថិតិយេនឌ័រ សម្រាប់ខេត្តកំពង់ធំ ត្បូងឃ្មុំ និងកំពង់ឆ្នាំង ចំណែកខេត្តកំពង់ចាម និងខេត្តសៀមរាបកំពុងបានធ្វើបច្ចុប្បន្នភាព។ |
| 1.7. "វិធីសាស្ត្រវិភាគខ្សែច្រវ៉ាក់តម្លៃដែលឆ្លើយតបនឹង យេនឌ័រ" បានបង្កើតនៅក្នុងដំណាក់កាលនៃការធ្វើផែនការសកម្មភាពសាកល្បងនៅថ្នាក់ក្រោមជាតិ និងបានចងក្រងនិងធ្វើបច្ចុប្បន្នភាពទៅក្នុងគោលការណ៍ណែនាំអំពី WEE។ | 1.7. វិធីសាស្ត្រវិភាគខ្សែច្រវ៉ាក់តម្លៃដែលឆ្លើយតបនឹងយេនឌ័រ ត្រូវបានបង្កើតឡើងព្រមទាំងបានធ្វើការកែសម្រួល និងបានអនុវត្តនៅក្នុងសកម្មភាពសាកល្បងរបស់ខេត្តកំពង់ធំ ត្បូងឃ្មុំ និងសៀមរាប។ |
| 1.8. MOWA/PDWA បានផ្តល់នូវគោលគំនិតជាមូលដ្ឋានស្តីអំពីការត្រួតពិនិត្យ និងវាយតម្លៃដែលឆ្លើយតបនឹងយេនឌ័រ (ផ្អែកលើគោលនយោបាយ និងផ្តល់តែផ្នែកណាដែលពាក់ព័ន្ធជាមួយ | 1.8. បានចែករំលែក គោលគំនិតជាមូលដ្ឋានស្តីអំពី |

| | |
|---|---|
| WEE) ជូនដល់ក្រសួង និងមន្ទីរពាក់ព័ន្ធដែលជាដៃគូ។<br><br>1.9. បានធ្វើការវាយតម្លៃសមត្ថភាពផ្នែកយេនឌ័រ លើកចុងក្រោយ។ | ការត្រួតពិនិត្យ និងការវាយតម្លៃដែលឆ្លើយតបទៅនឹងយេនឌ័រ (ផ្តែកលើគោលនយោបាយ) និងបានសម្របសម្រួលកិច្ចពិភាក្សាជាមួយសមាជិកក្រុមការងារបញ្ជ្រាបយេនឌ័រ(GMAG member) របស់ក្រសួងពាក់ព័ន្ធដែលជាដៃគូ ក្នុងកិច្ចសន្ទនាដែលបានអនុវត្តនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២២។<br>1.9. បានធ្វើការវាយតម្លៃសមត្ថភាពផ្នែកយេនឌ័រ លើកចុងក្រោយរបស់ MOWA និង PDWA នៅដើម ខែធ្នូ ឆ្នាំ២០២២។ |
| <**លទ្ធផលរំពឹងទុកទី ២**> តាមរយៈសកម្មភាពសាកល្បង យន្តការអនុវត្ត និងឧបករណ៍ដើម្បីលើកកម្ពស់ **WEE** ត្រូវបានពិនិត្យផ្ទៀងផ្ទាត់ថាមានប្រសិទ្ធភាពដោយក្រសួងកិច្ចការនារី / មន្ទីរកិច្ចការនារី និងក្រសួង/មន្ទីរដៃគូ។ | |
| (ការធ្វើផែនការ ការអនុវត្ត និងការត្រួតពិនិត្យសកម្មភាពលើកកម្ពស់ WEE **(**តាមរយៈសកម្មភាពសាកល្បង) នៅថ្នាក់ក្រោមជាតិ)<br><br>2-1 នៅខេត្តកំពង់ចាម បានធ្វើការត្រួតពិនិត្យ និងតាមដាន សកម្មភាពចិញ្ចឹមមាន់ដែលគាំទ្រដោយគម្រោង PGM2។<br>2-2 នៅខេត្តកំពង់ឆ្នាំង មន្ទីរកិច្ចការនារី (PDWA) និងមន្ទីរពាក់ព័ន្ធដែលជាដៃគូ រៀបចំផែនការ ចុះអនុវត្ត និងធ្វើការតាមដានត្រួតពិនិត្យសកម្មភាពលើកកម្ពស់ WEE ក្នុងវិស័យកសិកម្ម / ការចិញ្ចឹមមាន់ (ជាសកម្មភាព សាកល្បង) ហើយចែករំលែកលទ្ធផល និងបទពិសោធន៍ដែលទទួលបានតាមរយៈការអនុវត្តសកម្មភាពសាកល្បងនៅក្នុងកិច្ចប្រជុំក្រុមការងារ WEE។<br>2-3 នៅខេត្តសៀមរាប មន្ទីរកិច្ចការនារី (PDWA**)** និងមន្ទីរពាក់ព័ន្ធដែលជាដៃគូ រៀបចំផែនការ ចុះអនុវត្ត និង ចុះធ្វើការតាមដានត្រួតពិនិត្យសកម្មភាពលើកកម្ពស់ WEE ក្នុងវិស័យទេសចរណ៍ (ជាសកម្មភាពសាកល្បង) ហើយចែករំលែកលទ្ធផល និងបទពិសោធន៍ដែលទទួលបានតាមរយៈការអនុវត្តសកម្មភាពសាកល្បងនៅក្នុងកិច្ចប្រជុំក្រុមការងារ WEE ។<br>*(ការបញ្ជ្រាបទស្សនៈទានយេនឌ័រទៅក្នុងកម្មវិធី និងគម្រោងដែលមានស្រាប់ នៅថ្នាក់ក្រោមជាតិ)* | 2-1 បានធ្វើការត្រួតពិនិត្យ និងតាមដានសកម្មភាពចិញ្ចឹមមាន់ នៅក្នុងឆ្នាំទី១ របស់គម្រោង PGM-WEE។<br>2-2 PDWA និងមន្ទីរពាក់ព័ន្ធដែលជាដៃគូ បានរៀបចំផែនការ និងបានចុះអនុវត្ត ព្រមទាំងបានធ្វើការតាមដានត្រួតពិនិត្យ សកម្មភាពចិញ្ចឹមមាន់ នៅក្នុងខេត្តកំពង់ឆ្នាំងចាប់ពីខែធ្នូ ឆ្នាំ២០១៨ ដល់ខែកុម្ភៈ ឆ្នាំ២០២០។<br><br>2-3 បានរៀបចំផែនការ និងបានចុះអនុវត្ត ព្រមទាំងបានធ្វើការតាមដានត្រួតពិនិត្យ វគ្គបណ្តុះបណ្តាលជាសេរី ស្តីពីផែនការអាជីវកម្ម និងសកម្មភាពសម្រាប់ចុះតាមដានត្រួតពិនិត្យនានាដើម្បីលើកកម្ពស់ WEE នៅក្នុងវិស័យទេសចរណ៍ នៅខេត្តសៀមរាប ចាប់ពីខែឧសភា ឆ្នាំ២០១៩ ដល់ខែតុលា ឆ្នាំ២០២២។<br><br>2-4 សកម្មភាពបង្កើតប្រាក់ចំណូលដែល |

| | |
|---|---|
| 2-4 នៅខេត្តត្បូងឃ្មុំ និងកំពង់ធំ មន្ទីរកិច្ចការនារី (PDWA) និងមន្ទីរពាក់ព័ន្ធដែលជាដៃគូ ធ្វើការដាក់បញ្ចូលទស្សនទានយេនឌ័រទៅក្នុងកម្មវិធី និងគម្រោងដែលមានស្រាប់ ដើម្បីគាំទ្រដល់ស្ត្រីរស់នៅតំបន់ជនបទ និងក្រុមស្ត្រីចូលរួមនៅក្នុងវិស័យកសិកម្ម និងសិប្បកម្ម (សកម្មភាពសេដ្ឋកិច្ច) ហើយធ្វើការចែករំលែកលទ្ធផល មេរៀន និងបទពិសោធន៍ដែលទទួលបានតាមរយៈការអនុវត្តសកម្មភាពសាកល្បងនៅក្នុងកិច្ចប្រជុំក្រុមការងារ WEE ។ | មានស្រាប់របស់ស្ត្រីដែលរស់នៅតំបន់ជនបទ ទាំងនៅក្នុង វិស័យកសិកម្ម និងសិប្បកម្ម ត្រូវបានគាំទ្រហើយផ្តោតសំខាន់ទៅលើគោលគំនិតយេនឌ័រ និងទស្សនទាន WEE ដោយមន្ទីរកិច្ចការនារី (PDWA) និងមន្ទីរពាក់ព័ន្ធដែលជាដៃគូក្នុងខេត្តកំពង់ធំ និងខេត្តត្បូងឃ្មុំ ចាប់ពីខែធ្នូ ឆ្នាំ២០២១ ដល់ខែកញ្ញា ឆ្នាំ២០២២។ |
| 2-5 នៅខេត្តកំពង់ចាម និងកំពង់ឆ្នាំង មន្ទីរកិច្ចការនារី (PDWA) និងមន្ទីរពាក់ព័ន្ធដែលជាដៃគូ ធ្វើការវិភាគស្ថានភាពរបស់ស្ត្រីរស់នៅតំបន់ជនបទ និងក្រុមស្ត្រីនៅក្នុងវិស័យកសិកម្ម ដើម្បីសិក្សាស្វែងយល់អំពីតម្រូវការរបស់ពួកគេ និងពិនិត្យមើលវិធានការដែលមានប្រសិទ្ធភាពសម្រាប់គាំទ្រស្ត្រីឱ្យចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសេដ្ឋកិច្ច ព្រមទាំងចែករំលែកលទ្ធផល និងមេរៀនបទពិសោធន៍នៅក្នុងកិច្ចប្រជុំក្រុមការងារ WEE ។ | 2-5 បានអនុវត្តសកម្មភាពតាមដានសម្រាប់ការបញ្ជ្រាបយេនឌ័រទៅក្នុងសកម្មភាពបង្កើតប្រាក់ចំណូលដែលមានស្រាប់របស់ស្ត្រីរស់នៅតំបន់ជនបទ នៅក្នុងខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២១ ដល់ខែសីហា ឆ្នាំ២០២២។ |
| 2-6 នៅខេត្តសៀមរាប មន្ទីរកិច្ចការនារី (PDWA) និងមន្ទីរពាក់ព័ន្ធដែលជាដៃគូ ធ្វើការវិភាគស្ថានភាពរបស់ស្ត្រីរស់នៅតំបន់ជនបទ និងក្រុមស្ត្រីនៅក្នុងវិស័យទេសចរណ៍ ដើម្បីសិក្សាស្វែងយល់អំពីតម្រូវការរបស់ពួកគាត់ និងពិនិត្យមើលវិធានការដែលមានប្រសិទ្ធភាពសម្រាប់គាំទ្រស្ត្រីឱ្យចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសេដ្ឋកិច្ចព្រមទាំងចែករំលែកលទ្ធផល និងមេរៀនបទពិសោធន៍នៅក្នុងកិច្ចប្រជុំក្រុមការងារWEE។ | 2-6 បានធ្វើការវិភាគយេនឌ័រ ដើម្បីស្វែងយល់ពីតម្រូវការរបស់ស្ត្រីរស់នៅតំបន់ជនបទដែលធ្វើការនៅក្នុង វិស័យទេសចរណ៍(ដូចគ្នានឹងសកម្មភាពទី២-៣)។ វិធានការប្រកបដោយប្រសិទ្ធភាពត្រូវបានបង្កើតសម្រាប់ លើកកម្ពស់ជីវភាពរបស់ពួកគាត់ និងអនុវត្តជាសកម្មភាពសាកល្បងនៅក្នុងខេត្តសៀមរាប។ |
| *(ការគិតគូពិចារណាលើវិធានការដែលមានប្រសិទ្ធភាពសម្រាប់លើកកម្ពស់ WEE និងការចូលរួមដោយសកម្មរបស់ស្ត្រីនៅក្នុងសកម្មភាពសេដ្ឋកិច្ច)*<br>2-7 ផ្អែកលើសកម្មភាព ២-២-២-៦ យន្តការនៃការអនុវត្ត តាមស្ថាប័ន និងឧបករណ៍អនុវត្តសម្រាប់លើកកម្ពស់ WEE នៅថ្នាក់ក្រោមជាតិ ត្រូវបានចងក្រងនិងធ្វើបច្ចុប្បន្នភាពនៅក្នុងគោលការណ៍ណែនាំស្តីអំពី WEE។ | 2-7 គោលការណ៍ណែនាំស្តីអំពី WEE ត្រូវបានចងក្រង និងអនុម័តដោយ MOWA នៅក្នុងខែធ្នូ ឆ្នាំ២០២២។ |

| **<លទ្ធផលរំពឹងទុកទី ៣>** អនុសាសន៍ (គោលគំនិត និងមេរៀនទទួលបាន) ដើម្បីអនុវត្ត/រៀបចំគោលនយោបាយឱ្យឆ្លើយតបនឹងយេនឌ័រ ត្រូវបានទទួលស្គាល់ដោយក្រសួង និងមន្ទីរពាក់ព័ន្ធដែលជាដៃគូ និងក្រុមការងារយេនឌ័ររបស់ គ.ជ.អ.ប តាមរយៈការពិភាក្សាយ៉ាងសកម្មជាមួយក្រសួងកិច្ចការនារី / មន្ទីរកិច្ចការនារី។ | |
|---|---|
| 3-1 ការដាក់បញ្ចូលសកម្មភាពគម្រោងទៅក្នុងផែនការ នារីរតនៈទី V និងគោលនយោបាយយេនឌ័ររបស់ គ.ជ.អ.ប តាមរយៈការសម្របសម្រួល និងកិច្ចសហការជាមួយ MOWA។ | 3-1 បានដាក់បញ្ចូលសកម្មភាពដែលពាក់ព័ន្ធទៅក្នុងផែនការនារីរតនៈទី V។ |
| 3-2 ក្រសួងកិច្ចការនារី ធ្វើការចែករំលែកអំពីវឌ្ឍនភាព លទ្ធផល បទពិសោធន៍ របកគំហើញ និងមេរៀនល្អៗ ដែលទទួលបានតាមរយៈការអនុវត្តសកម្មភាពគម្រោង ជាមួយនឹងក្រសួងពាក់ព័ន្ធដែលជាដៃគូ និងធ្វើការ តស៊ូមតិដើម្បីលើកកម្ពស់ WEE នៅថ្នាក់ក្រោមជាតិតាមរយៈកិច្ចប្រជុំក្រុមការងារបច្ចេកទេសយេនឌ័រ (GMAG) និងក្រុមការងារ WEE នៃក្រុមការងារបច្ចេកទេសយេនឌ័រ (TWG-G WEE)។ | 3-2 លទ្ធផល និងរបកគំហើញសំខាន់ៗរបស់គម្រោង PGM-WEE បានចែករំលែកនៅក្នុងកិច្ចប្រជុំក្រុមការងារ WEE នៃក្រុមការងារបច្ចេកទេសយេនឌ័រ (TWG-G WEE) នៅក្នុងខែតុលា ឆ្នាំ ២០២២។ |
| 3-3 អនុសាសន៍សម្រាប់ការលើកកម្ពស់ WEE នៅថ្នាក់ក្រោមជាតិ ត្រូវបានពិភាក្សា និងចងក្រងដោយក្រុមការងារក្រសួងកិច្ចការនារី។ | 3-3 បានពិភាក្សាអំពីអនុសាសន៍សម្រាប់ការលើកកម្ពស់ WEEនៅថ្នាក់ក្រោមជាតិ នៅក្នុងសិក្ខាសាលាចែករំលែកបទពិសោធន៍គម្រោង (retreat program) នៅក្នុងខែកក្កដា ឆ្នាំ២០២២។ |
| 3-4 ចែករំលែកអនុសាសន៍ដែលបានចងក្រង នៅក្នុងកិច្ចប្រជុំ TWG-G WEE / GMAG។ | 3-4 បានចែករំលែក និងពិភាក្សាអំពីគន្លឹះក្នុងការលើកកម្ពស់ WEE នៅថ្នាក់ក្រោមជាតិនៅក្នុងកិច្ចសន្ទនាជាមួយសមាជិក GMAG ក្នុងខែវិច្ឆិកា ឆ្នាំ២០២២។ |
| 3-5 ការពិភាក្សា និងការសម្របសម្រួលយ៉ាងសកម្មត្រូវបានធ្វើឡើងជាមួយក្រសួងពាក់ព័ន្ធដែលជាដៃគូ និងក្រុមការងារយេនឌ័ររបស់ NCDD (ដែលរួមមាននាយកដ្ឋានសមភាពយេនឌ័ររបស់ MOWA និង NCDD ដើម្បីដាក់បញ្ចូលអនុសាសន៍ដែលបានផ្តល់ទៅក្នុងផែនការតាមវិស័យ / ផែនការប្រចាំឆ្នាំ /ផែនការសកម្មភាពរបស់ក្រសួងពាក់ព័ន្ធដែលជាដៃគូ និងសម្រាប់គោលនយោបាយយេនឌ័ររបស់ NCDD។ | 3-5 បាន ពិភាក្សាជាបន្តបន្ទាប់ជាមួយក្រុមការងារយេនឌ័រ របស់ NCDD អំពីរបៀបក្នុងការដាក់បញ្ចូលបទពិសោធន៍របស់គម្រោង PGM-WEE ទៅក្នុងផែនការនៃគោលនយោបាយយេនឌ័ររបស់ NCDD តាំងពីខែកុម្ភៈ ឆ្នាំ២០២២។ |
| 3-6 សិក្ខាសាលាចែករំលែកបទពិសោធន៍ (លទ្ធផល) ដើម្បីចែករំលែកឱ្យបានទូលំទូលាយនូវអនុសាសន៍ដែលបានអនុម័ត (នៅក្នុងសកម្មភាព ៣-៤) និងបានធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្តីអំពី WEE (សកម្មភាព ២-៧) | 3-6 បានរៀបចំសិក្ខាសាលាចែករំលែកបទពិសោធន៍ នៅខែធ្នូ ឆ្នាំ ២០២២ ដើម្បីចែករំលែកនូវគោលគំនិតសំខាន់ៗ និងបទពិសោធន៍របស់គម្រោង PGM-WEE សម្រាប់ការលើកកម្ពស់ |

| | | | |
|---|---|---|---|
| | ដោយសហការជាមួយមន្ត្រីដៃគូនៃក្រសួងកិច្ចការនារី (MOWA) ក៏ដូចជាចែករំលែកផងដែរនូវលទ្ធផល និងមេរៀនបទពិសោធន៍ដែលទទួលបានពីសកម្មភាពគម្រោងជាមួយនឹងក្រសួងពាក់ព័ន្ធដែលជាសដៃគូ។ | | WEE នៅថ្នាក់ក្រោមជាតិ និងបានចែករំលែកអំពីប្រធានបទ ក៏ដូចជាមាតិកានៃគោលការណ៍ណែនាំស្តីអំពី WEE ដែលបានធ្វើបច្ចុប្បន្នភាពជាមួយនឹងមន្ទីរកិច្ចការនារី ទូទាំង ២៥ រាជធានី/ខេត្ត ។ |
| 3-7 | សិក្ខាសាលាថ្នាក់តំបន់ដើម្បីចែករំលែកសមិទ្ធិផល លទ្ធផល ការអនុវត្តល្អៗ និងមេរៀនបទពិសោធន៍ដែលទទួលបានពីសកម្មភាពគម្រោង ក៏ដូចជាការផ្លាស់ប្តូរបទពិសោធន៍ក្នុងចំណោមបណ្តាប្រទេសដែលជាសមាជិក ASEAN។ | 3-7 | ដោយសារមានវេទិកា និងកិច្ចប្រជុំអាស៊ានជាច្រើន ត្រូវអនុវត្តនៅក្នុងខែតុលា និងខែវិច្ឆិកា ឆ្នាំ២០២២ដូច្នេះក្រសួងកិច្ចការនារី (MOWA) មិនអាចធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំបន្ថែមទៀតបានទេ។អាស្រ័យហេតុនេះ គម្រោងបានសម្រេចផ្តោតលើការរៀបចំសិក្ខាសាលាចែករំលែកបទពិសោធន៍ (សកម្មភាពទី៣-៦) ដោយបន្ថែមខ្លឹមសារសំខាន់ៗ និងចំនួនអ្នកចូលរួម។ |

២.២. សមិទ្ធិផលរបស់គម្រោង

២.២.១. លទ្ធផល និងសូចនាករ

(តម្លៃនៃគោលដៅ និងតម្លៃជាក់ស្តែងដែលសម្រេចបាននៅពេលបញ្ចប់គម្រោង)

១). **<u>លទ្ធផលរំពឹងទុកទី ១៖</u>** សមត្ថភាពរបស់ MOWA / PDWA ក្នុងការស្វែងរកការគាំទ្រមតិ និងការសម្របសម្រួលត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ WEE នៅថ្នាក់ក្រោមជាតិ។

| សូចនាករ | កម្រិតនៃសមិទ្ធិផលដែលសម្រេចបាន |
|---|---|
| 1. សមត្ថភាពរបស់មន្ត្រីដៃគូនៃក្រសួងកិច្ចការនារី / មន្ទីរកិច្ចការនារីក្នុងការស្វែងរកការគាំទ្រមតិ និងការសម្របសម្រួលត្រូវបានពង្រឹង ដូចដែលបានកំណត់នៅក្នុងការប៉ាន់ប្រមាណសមត្ថភាពផ្នែកយេនឌ័រ។ | • យោងតាមការវាយតម្លៃអំពីកម្រិតនៃការយល់ដឹង បន្ទាប់ពីសិក្ខាសាលាចែករំលែកបទពិសោធន៍ (retreat program) ដែលបានរៀបចំនៅក្នុងខែកក្កដា ឆ្នាំ ២០២២ បានបង្ហាញថា សមត្ថភាព និងការយល់ដឹងរបស់ MOWA និង PDWA នៅក្នុងខេត្តគោលដៅទាំង៥ មានភាពប្រសើរឡើងលើគ្រប់ទិដ្ឋភាព និងជំហាននៃវដ្តគ្រប់គ្រងគម្រោងដែលឆ្លើយតបនឹងយេនឌ័រ (ការវិភាគស្ថានភាព/បញ្ហា ការធ្វើផែនការ ការអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃ)។<br>• យោងតាមលទ្ធផលនៃការវាយតម្លៃ (self-evaluation) លើកចុងក្រោយ ដែលបានធ្វើនៅក្នុងខែធ្នូ ឆ្នាំ២០២២ បានបង្ហាញថា |

| | |
|---|---|
| | សមត្ថភាពក្នុងការបញ្ជ្រាបយេនឌ័ររបស់ក្រសួង / មន្ទីរកិច្ចការនារី នៅគ្រប់ចំណុចទាំង៥ មានភាពប្រសើឡើង។     |

**២). លទ្ធផលរំពឹងទុកទី ២៖** តាមរយៈសកម្មភាពសាកល្បង យន្តការអនុវត្ត និងឧបករណ៍ដើម្បីលើកកម្ពស់ WEE ត្រូវបានពិនិត្យផ្ទៀងផ្ទាត់ថាមានប្រសិទ្ធភាពដោយក្រសួងកិច្ចការនារី / មន្ទីរកិច្ចការនារី និងក្រសួង/មន្ទីរពាក់ព័ន្ធដែលជាដៃគូ។

| សូចនាករ | កម្រិតនៃសមិទ្ធផលដែលសម្រេចបាន |
|---|---|
| 2.1 ឧបករណ៍អនុវត្តសម្រាប់លើកកម្ពស់ WEE នៅថ្នាក់ក្រោមជាតិ ត្រូវបានផ្ទៀងផ្ទាត់ដោយមន្ត្រីដៃគូក្រសួងកិច្ចការនារី មន្ទីរកិច្ចការនារី និងមន្ទីរពាក់ព័ន្ធដែលជាដៃគូ។ | • ឧបករណ៍សំខាន់ៗដែលធ្វើការផ្ទៀងផ្ទាត់ដោយមន្ត្រីដៃគូនៃក្រសួង / មន្ទីរកិច្ចការនារី និងមន្ទីរពាក់ព័ន្ធដែលជាដៃគូតាម រយៈ: កិច្ចប្រជុំបច្ចេកទេស(មុនពេលចុះអនុវត្តសកម្មភាពសាកល្បង) ការរៀនសូត្របណ្តើរ និងធ្វើការបណ្តើរនៅតាមភូមិគោលដៅ និងវគ្គបណ្តុះបណ្តាលបំប៉នបន្ថែម (ឧទាហរណ៍៖ វគ្គបណ្តុះបណ្តាលយេនឌ័រ សិក្ខាសាលាចែករំលែកបទពិសោធន៍ សិក្ខាសាលាបញ្ជ្រាបយេនឌ័រ)។ |
| 2.2 តួនាទី និងមុខងាររបស់ក្រុមការងារ WEE នៅក្នុងគម្រោងត្រូវបានរៀបចំ និងដាក់បញ្ចូល នៅក្នុងគោលការណ៍ណែនាំស្តីអំពី WEE ដែលបានធ្វើបច្ចុប្បន្នភាព។ | • ផ្អែកលើលទ្ធផលនៃការពិភាក្សាក្នុងចំណោមសមាជិកក្រុមការងារ WEE នៅតាមខេត្តគោលដៅនីមួយៗ ដែលបានឆ្លងយោបល់ និងសុំការអនុម័តពីឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត ក្នុងការរៀបចំមុខងារ និងរចនាសម្ព័ន្ធរបស់ក្រុមការងារ WEE ក្នុងនោះមានខេត្តចំនួន៤ ដែលសម្រេចដាក់ឱ្យស្ថិតនៅក្រោម |

| | |
|---|---|
| | គ.ក.ស.ក គឺមាន(កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ និងត្បូងឃ្មុំ) ចំណែកខេត្តសៀមរាប គឺសម្រេចដាក់នៅក្រោមរដ្ឋបាលខេត្ត។<br>• មុខងាររបស់ក្រុមការងារ WEE ត្រូវបានចងក្រងនៅក្នុងគោលការណ៍ណែនាំស្តីពី WEE។ |

**៣). លទ្ធផលរំពឹងទុក ទី៣៖** អនុសាសន៍ (គោលគំនិត និងមេរៀនទទួលបាន) ដើម្បីអនុវត្ត/រៀបចំគោលនយោបាយឱ្យឆ្លើយតបនឹងយេនឌ័រ ត្រូវបានទទួលស្គាល់ដោយក្រសួង និងមន្ទីរពាក់ព័ន្ធដែលជាដៃគូ និងក្រុមការងារយេនឌ័ររបស់ NCDD។

| សូចនាករ | កម្រិតនៃសមិទ្ធផលដែលសម្រេចបាន |
|---|---|
| អនុសាសន៍ (គោលគំនិត និងមេរៀនបទពិសោធន៍) ត្រូវបានទទួលស្គាល់ដោយក្រសួងពាក់ព័ន្ធដែលជាដៃគូ ក្រុមការងារយេនឌ័ររបស់ NCDD និងមន្ទីរពាក់ព័ន្ធដែលជាដៃគូ។ | • អនុសាសន៍ត្រូវបានចងក្រង និងទទួលស្គាល់ដោយក្រសួង និងមន្ទីរពាក់ព័ន្ធដែលជាដៃគូ និងក្រុមការងារយេនឌ័រនៃ NCDD នៅក្នុងសិក្ខាសាលាចែករំលែកបទពិសោធន៍ កាលពីខែកក្កដា ឆ្នាំ២០២២ កន្លងមក។<br>• ក្រសួងពាក់ព័ន្ធបានបញ្ជាក់ពីសារៈសំខាន់នៃការប្រើប្រាស់ចំណុចគន្លឹះៗ និងមេរៀនដែលទទួលបានពីគម្រោងសម្រាប់ការលើកកម្ពស់ WEE ទៅក្នុងសកម្មភាព / គម្រោងដែលមានស្រាប់តាមរយៈកិច្ចសន្ទនាជាមួយក្រុមការងារបញ្ជ្រាបយេនឌ័រ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២២។<br>• NCDD ទទួលស្គាល់ថា គោលគំនិត និងមេរៀនដែលទទួលបានតាមរយៈការអនុវត្តគម្រោង PGM-WEEពិតជាមានសារៈសំខាន់ណាស់ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការបញ្ជ្រាបយេនឌ័រនៅថ្នាក់ខេត្តស្របតាមការអនុវត្តគោលនយោបាយយេនឌ័ររបស់ NCDD។ |

២.២.២. គោលបំណងគម្រោង និងសូចនាករ

(តម្លៃនៃគោលដៅ និងតម្លៃជាក់ស្តែងដែលសម្រេចបាននៅពេលបញ្ចប់គម្រោង)

**គោលបំណងគម្រោង៖** យន្តការបញ្ជ្រាបយេនឌ័រត្រូវបានពង្រឹង*2 ដើម្បីលើកកម្ពស់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (WEE) នៅថ្នាក់ក្រោមជាតិ ដោយក្រសួង / មន្ទីរពាក់ព័ន្ធដែលជាដៃគូ តាមរយៈការស្វែងរកការគាំទ្រមតិ និងការសម្របសម្រួលដោយក្រសួង / មន្ទីរកិច្ចការនារី (MOWA/PDWA)។

| សូចនាករ | កម្រិតនៃសមិទ្ធផលដែលសម្រេចបាន |
|---|---|
| 1. MOWA / PDWA ធ្វើការស្វែងរកការគាំទ្រមតិ និងសម្របសម្រួលជាមួយក្រសួង និងមន្ទីរពាក់ព័ន្ធដែលជាដៃគូ ដើម្បីរៀបចំផែនការ និងអនុវត្តកម្មវិធី | • តាមរយៈសិក្ខាសាលាចែករំលែកបទពិសោធន៍ (Retreat Program) ដែលបានរៀបចំនៅខែកក្កដា ឆ្នាំ ២០២២ និងសិក្ខាសាលាជាសើរី |

| | |
|---|---|
| និងគម្រោងដែលឆ្លើយតបនឹងយេនឌ័រ។ | ស្ដីពីការបញ្ជ្រាបយេនឌ័រនៅក្នុងខេត្តគោលដៅនីមួយៗ បានបញ្ជាក់ឱ្យឃើញច្បាស់នូវវិធីសាស្ត្រជាក់ស្ដែង និងភាពចាំបាច់ក្នុងការដាក់បញ្ចូលទស្សនៈទានយេនឌ័រ និង/ឬទស្សនទាន WEE ទៅក្នុងកម្មវិធី និងគម្រោងដែលមានស្រាប់ តាមរយៈការសម្របសម្រួលរបស់ MOWA និង PDWA។<br>• មន្ទីរកិច្ចការនារី និងមន្ទីរពាក់ព័ន្ធមួយចំនួនបានចាប់ផ្ដើមពិភាក្សា និងសម្របសម្រួលដើម្បីដាក់បញ្ចូលទស្សនទាន យេនឌ័រ ឬទស្សនទាន WEE ទៅក្នុងគម្រោង / សកម្មភាពដែលមានស្រាប់ (ឧទាហរណ៍៖ គម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច(AIMS), កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE) ដែលគាំទ្រដោយ IFAD/MAFF និងគម្រោងភូមិមួយផលិតផលមួយ (OVOP) របស់មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍។<br>• របកគំហើញ និងមេរៀនដែលទទួលបានតាមរយៈគម្រោង PGM-WEE ត្រូវបានចែករំលែកនៅក្នុងកិច្ចប្រជុំក្រុមការងារWEE នៃក្រុមការងារបច្ចេកទេសយេនឌ័រ (TWG-G WEE) ដែលបានរៀបចំនៅក្នុងខែតុលា ឆ្នាំ២០២២។ |
| 2. កិច្ចប្រជុំ គកសក ដើរតួជាវេទិកាសម្រាប់មន្ទីរកិច្ចការនារី និងមន្ទីរពាក់ព័ន្ធ ពិភាក្សា និងតាមដានកម្មវិធី និងគម្រោងឆ្លើយតបនឹងយេនឌ័រដើម្បីលើកកម្ពស់ WEE នៅក្នុងខេត្តគោលដៅទាំងអស់របស់គម្រោង។ | • ផ្អែកលើការសម្រេចចិត្តក្នុងការរៀបចំមុខងារ និងរចនាសម្ព័ន្ធក្រុមការងារ WEE នៅក្នុងខេត្តគោលដៅ ដែលត្រូវបានអនុម័ត ដោយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត ដូច្នេះវិធានការចាំបាច់មួយចំនួនដែលត្រូវអនុវត្តដើម្បីធ្វើឱ្យក្រុមការងារ WEE ដំណើរការទៅបាន រួមទាំងការពិនិត្យទៅលើសមាសភាពសមាជិកក្រុមការងារសារជាថ្មី និងធានាថាមានថវិកាសម្រាប់អនុវត្តក្រោមការដឹកនាំរបស់លោកជំទាវប្រធាន គកសក និង/ឬលោកជំទាវអភិបាលរងនៃគណៈអភិបាលខេត្ត ដោយមានការសម្របសម្រួលពី PDWA ។ |

| | |
|---|---|
| 3. គោលការណ៍ណែនាំស្តីពី WEE ដែលបានធ្វើបច្ចុប្បន្នភាពត្រូវបានអនុម័តដោយ MOWA | • គោលការណ៍ណែនាំស្តីអំពី WEE ត្រូវបានធ្វើបច្ចុប្បន្នភាព និងអនុម័តដោយ MOWA ក្នុងខែធ្នូ ឆ្នាំ ២០២២។ |
| 4. ក្រសួងដៃគូ និងក្រុមការងារយេនឌ័ររបស់ NCDD ដាក់បញ្ចូលឧបករណ៍អនុវត្ត ឬអនុសាសន៍ដើម្បីលើកកម្ពស់ WEE យ៉ាងតិច១ ទៅក្នុងគម្រោង និងសកម្មភាពរបស់ខ្លួន។ | • ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រសួងពាណិជ្ជកម្ម ទទួលស្គាល់ និងគាំទ្រដល់មន្ទីរក្នុងការដាក់បញ្ចូលឧបករណ៍អនុវត្តសម្រាប់ការបណ្តុះបណ្តាលយេនឌ័រទៅក្នុងគម្រោង ឬកម្មវិធីដែលផ្តល់មូលនីធិដោយដៃគូអភិវឌ្ឍផ្សេងៗ (ឧទាហរណ៍៖ IFAD, ADB)។<br>• ក្រសួងទេសចរណ៍ និងក្រសួងកិច្ចការនារី បានចុះកិច្ចព្រមព្រៀងលើការរៀបចំផែនការសកម្មភាពរួមគ្នា សម្រាប់គោលនយោបាយអេកូទេសចរណ៍ឆ្លើយតបនឹងយេនឌ័រ រួមជាមួយនឹងឧបករណ៍ និងចំណុចគន្លឹះក្នុងការអនុវត្តរបស់គម្រោង PGM-WEE និងបានយល់ព្រមរៀបចំអនុស្សរណៈនៃការយោគយល់គ្នា(MOU) ហើយថែមទាំងបានឯកភាពក្នុងការដាក់បញ្ចូល ក្រសួងកិច្ចការនារីជាសមាជិកនៃលេខាធិការដ្ឋានគណកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍។<br>• ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានទទួលស្គាល់ និងគាំទ្រមន្ទីរក្នុងការអនុវត្តការបញ្ចូលទស្សនទានយេនឌ័រ និង WEE ទៅក្នុងគម្រោងដែលមានស្រាប់ និងសេវារដ្ឋបាលដើម្បីធ្វើឱ្យកាន់តែឆ្លើយតបនឹងយេនឌ័រ។<br>• NCDD ទទួលស្គាល់ថាលទ្ធផល និងបទពិសោធន៍របស់គម្រោង PGM-WEE ត្រូវបន្តយកទៅពិភាក្សាក្នុងកិច្ចប្រជុំនានាជាមួយនឹងក្រសួងកិច្ចការនារីសម្រាប់ការរៀបចំផែនការ យុទ្ធសាស្ត្រ និងការអនុវត្តគោលនយោបាយសមភាពយេនឌ័រ របស់ NCDD។ |

២.៣. ប្រវត្តិ និងការកែសម្រួលតារាងម៉ាទ្រិករៀបចំគម្រោង (PDM)

២.៣.១. ខែមករា ឆ្នាំ២០២០ (សូមមើល ឧបសម្ព័ន្ធទី ៣-២)

(១). រយៈពេលអនុវត្តគម្រោង

| ពីមុន **(ver.0)** | កំណែថ្មី **(ver.1)** |
|---|---|
| រយៈពេល ៥ឆ្នាំ | រយៈពេល ៥ឆ្នាំ (ពីខែកុម្ភៈ ឆ្នាំ២០១៧ ដល់ខែកុម្ភៈ ឆ្នាំ២០២២) |
| **មូលហេតុ៖** បញ្ជាក់អំពីពេលវេលាចាប់ផ្តើម និងខែឆ្នាំបញ្ចប់ជាក់លាក់ | |

(២). តំបន់គោលដៅ

| ពីមុន **(ver.0)** | កំណែថ្មី **(ver.1)** |
|---|---|
| រាជធានីភ្នំពេញ និងខេត្តគោលដៅចំនួន៥ ដែលបានជ្រើសរើស | រាជធានីភ្នំពេញ និងខេត្តគោលដៅចំនួន៥ ដែលបានជ្រើសរើស រួមមាន៖ (កំពង់ឆ្នាំង កំពង់ធំ សៀមរាប ត្បូងឃ្មុំ និងកំពង់ចាម) |
| **មូលហេតុ៖** បញ្ជាក់ពីឈ្មោះ និងខេត្តគោលដៅ | |

(៣). ក្រុមគោលដៅ

| ពីមុន **(ver.0)** | កំណែថ្មី **(ver.1)** |
|---|---|
| ក្រុមគោលដៅប្រយោល: ស្ត្រី និងបុរស នៅក្នុងខេត្តគោលដៅ | អ្នកទទួលផល៖ ស្ត្រី និងបុរសនៅក្នុងខេត្តគោលដៅ |
| **មូលហេតុ៖** ស្ត្រី និងបុរសនៅក្នុងភូមិដែលបានជ្រើសរើសក្នុងខេត្តគោលដៅ មិនមែនជាក្រុមគោលដៅប្រយោលទេ ប៉ុន្តែជាអ្នកទទួលផលពីសកម្មភាពរបស់គម្រោង។ | |

(៤). គោលដៅរួម

| ពីមុន **(ver.0)** | កំណែថ្មី **(ver.1)** |
|---|---|
| <**សេចក្តីអធិប្បាយសង្ខេប**><br>ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី(WEE) ត្រូវបានលើកកម្ពស់តាមរយៈកម្មវិធី និងគម្រោងឆ្លើយតបនឹងយេនឌ័រ ដែលត្រូវអនុវត្តដោយក្រសួងពាក់ព័ន្ធ / មន្ទីរនានា តាមរយៈការស្វែងរកការគាំទ្រមតិ និងការសម្របសម្រួលពីក្រសួងកិច្ចការនារី (MOWA) **/** មន្ទីរកិច្ចការនារីខេត្ត (PDWA) នៅទូទាំង ២៥ រាជធានី ខេត្ត នៅប្រទេសកម្ពុជា។ | <**សេចក្តីអធិប្បាយសង្ខេប**><br>ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (WEE) ត្រូវបានលើកកម្ពស់តាមរយៈកម្មវិធី និងគម្រោងឆ្លើយតបនឹងយេនឌ័រ ដែលត្រូវអនុវត្តដោយក្រសួង/មន្ទីរពាក់ព័ន្ធ តាមរយៈការស្វែងរកការគាំទ្រមតិ និងការសម្របសម្រួលពីក្រសួងកិច្ចការនារី (MOWA) **/** មន្ទីរកិច្ចការនារីខេត្ត (PDWA) នៅក្នុងខេត្តគោលដៅ និងខេត្តមិនមែនគោលដៅ។ |
| **មូលហេតុ៖**<br>វាមិនមែនជាទ្រឹស្តីដែលសន្មត់ថាលទ្ធផលគម្រោងអាចនឹងធ្វើការផ្សព្វផ្សាយគ្រប់ខេត្តមិនមែនគោលដៅទាំងអស់<br>និងអាចប្រាកដបានថាការអនុវត្តនៅក្នុងខេត្តទាំងនោះប្រព្រឹត្តទៅបានបន្ទាប់ពីគម្រោងបញ្ចប់បានប៉ុន្មានឆ្នាំនោះទេ។ | |
| <**សូចនាករ**><br>កម្មវិធី និងគម្រោងដែលឆ្លើយតបនឹងយេនឌ័រ ត្រូវបានរៀបចំ និងអនុវត្តដោយក្រសួងពាក់ព័ន្ធតាមរយៈសិក្ខាសាលាស្តីពីវិធី | <**សូចនាករ**><br>១. ចំនួនកម្មវិធី និងគម្រោងឆ្លើយតបនឹងយេនឌ័រ ត្រូវបានរៀបចំ និងអនុវត្ត ដើម្បីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដ |

<table>
<tr><td>សាស្ត្ររៀបចំគោលនយោបាយ ផែនការ កម្មវិធីនិងគម្រោងឆ្លើយតបនឹងយេនឌ័រ (PGM Method) ដែលសម្របសម្រួល ដោយក្រសួងកិច្ចការនារី (MOWA) / មន្ទីរកិច្ចការនារីខេត្ត (PDWA) នៅ ទូទាំង ២៥ រាជធានី ខេត្ត នៅប្រទេសកម្ពុជា។</td><td>ល់ស្ត្រី ផ្អែកតាមគោលការណ៍ណែនាំស្តីពី WEE ដែលបានធ្វើបច្ចុប្បន្នភាព និងគោលការណ៍ណែនាំស្តីពីវិធីសាស្ត្ររៀបចំ គោលនយោបាយ ផែនការ កម្មវិធីនិងគម្រោងឆ្លើយតបយេនឌ័រ (PGM Method) នៅក្នុងខេត្តគោលដៅ និងខេត្តមិនមែនគោលដៅ។<br>២. គកសក ដំណើការជាវេទិកាសម្រាប់មន្ទីរកិច្ចការនារី និងមន្ទីរពាក់ព័ន្ធ ពិភាក្សា និងតាមដាន កម្មវិធី និងគម្រោងឆ្លើយតបនឹងយេនឌ័រ ដែលអនុវត្តនៅខេត្តមិនមែនគោលដៅ។<br>៣. ក្រសួងដៃគូទាំងអស់ និង គជអប ដាក់បញ្ចូលអនុសាសន៍យ៉ាងតិច១ ទៅក្នុងគោលនយោបាយ/ផែនការវិស័យរបស់ខ្លួន ឬគោលនយោបាយ/ផែនការយេនឌ័ររបស់ គជអប ព្រមទាំងអនុវត្តកម្មវិធីនិងគម្រោងដែលឆ្លើយតបនឹងយេនឌ័រ ដើម្បីលើក កម្ពស់ WEE នៅថ្នាក់ក្រោមជាតិ។</td></tr>
<tr><td colspan="2">មូលហេតុះ បញ្ជាក់ពីគោលបំណងកម្មវិធី និងគម្រោងឆ្លើយតបយេនឌ័រ និងឯកសារយោងនៅពេលរៀបចំផែនការ និង ការអនុវត្ត ព្រមទាំងកំណត់គោលដៅឱ្យបានច្បាស់។<br>បន្ថែមសូចនាករសម្រាប់គោលដៅរួមដែលត្រូវសម្រេចបាន។</td></tr>
<tr><td><<b>មធ្យោបាយផ្ទៀងផ្ទាត់</b>><br>1. របាយការណ៍សិក្ខាសាលា ស្តីពីវិធីសាស្ត្រ PGM<br>2. របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក)</td><td><<b>មធ្យោបាយផ្ទៀងផ្ទាត់</b>><br>1-1 របាយការណ៍ប្រចាំឆ្នាំរបស់ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គកសក)<br>1-2 ផែនការអភិវឌ្ឍន៍ / ផែនការវិនិយោគខេត្ត<br>1-3 កំណត់ហេតុកិច្ចប្រជុំ និងរបាយការណ៍ គកសក<br>1-4 គោលនយោបាយ និងផែនការតាមវិស័យ និងគោលនយោបាយ / ផែនការយេនឌ័ររបស់ គជអប</td></tr>
<tr><td colspan="2">មូលហេតុះ បន្ថែមមធ្យោបាយផ្ទៀងផ្ទាត់ឱ្យស្របតាមសូចនាករ</td></tr>
</table>

(៥) គោលបំណងគម្រោង

| ពីមុន **(ver.0)** | កំណែថ្មី **(ver.1)** |
|---|---|
| <**មធ្យោបាយផ្ទៀងផ្ទាត់**><br>យន្តការបញ្ជ្រាបយេនឌ័រដើម្បីលើកកម្ពស់ WEE នៅថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដោយក្រសួង/មន្ទីរពាក់ព័ន្ធដែលជាដៃគូ តាមរយៈការស្វែងរកការគាំទ្រមតិ និងសម្របសម្រួលពីក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី។ | <**មធ្យោបាយផ្ទៀងផ្ទាត់**><br>យន្តការបញ្ជ្រាបយេនឌ័រដើម្បីលើកកម្ពស់ WEE នៅថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដោយក្រសួង/មន្ទីរពាក់ព័ន្ធដែលជាដៃគូ តាមរយៈការស្វែងរកការគាំទ្រមតិ និងសម្របសម្រួលពីក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី។<br><br>* "<u>ពង្រឹងយន្តការបញ្ជ្រាបយេនឌ័រ</u>" |

| | |
|---|---|
| | យន្តការចែកចេញជា ៣ ចំណុច សំខាន់ៗ៖ ១).សមត្ថភាពរបស់មន្ត្រីក្រសួងកិច្ចការនារី/មន្ទីរកិច្ចការនារី ក្នុងការស្វែងរកការគាំទ្រមតិ និងសម្របសម្រប ២). យន្តការអនុវត្ត និងឧបករណ៍សម្រាប់អនុវត្តគោលនយោបាយស្តីពី WEE នៅថ្នាក់ក្រោមជាតិ និង ៣).អនុសាសន៍សម្រាប់បង្កើត និងអនុវត្តន៍គោលនយោបាយឆ្លើយតបនឹងយេនឌ័រសម្រាប់ការលើកកម្ពស់ WEE។ |
| **មូលហេតុ៖** "ពង្រឹងយន្តការបញ្ជ្រាបយេនឌ័រ" ត្រូវបានកំណត់ | |
| <**សូចនាករ**><br>1. "គោលការណ៍ណែនាំស្តីពី WEE តាមរយៈការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ" ត្រូវបានអនុម័ត និងបោះពុម្ពចែកចាយ។<br>2. ផែនការពង្រីកបន្ថែមនូវយន្តការបញ្ជ្រាបយេនឌ័រ ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការប្រចាំឆ្នាំ ឬផែនការនារីរតនៈ(ផែនការរយៈពេល៥ឆ្នាំ) របស់ក្រសួងកិច្ចការនារី។ | <**សូចនាករ**><br>1. ក្រសួង/មន្ទីរកិច្ចការនារី ធ្វើការស្វែងរកការគាំទ្រមតិ និងសម្របសម្រួលជាមួយក្រសួង / សមន្ទីរពាក់ព័ន្ធដែលជាដៃគូ ដើម្បីធ្វើឱ្យការរៀបចំផែនការ ក៏ដូចជាការអនុវត្តគម្រោង/កម្មវិធីឆ្លើយតបនឹងយេនឌ័រ។<br>2. កិច្ចប្រជុំ គកសក គឺជាវេទិកាសម្រាប់មន្ទីរកិច្ចការនារី និងមន្ទីរពាក់ព័ន្ធដែលជាដៃគូពិភាក្សា និងតាមដានគម្រោង/កម្មវិធីឆ្លើយតបនឹងយេនឌ័រសម្រាប់ការលើកកម្ពស់ WEE នៅក្នុងខេត្តគោលដៅទាំងអស់របស់គម្រោង។<br>3. គោលការណ៍ណែនាំស្តីពី WEE បានធ្វើបច្ចុប្បន្នភាព និងអនុម័ត ដោយក្រសួងកិច្ចការនារី។<br>4. ក្រសួងពាក់ព័ន្ធដែលជាដៃគូ និងក្រុមការងារយេនឌ័រនៃ NCDD ដាក់បញ្ចូលឧបករណ៍អនុវត្ត ឬ អនុសាសន៍ដើម្បីលើកកម្ពស់ WEE យ៉ាងតិច១ ទៅក្នុងគម្រោង និងសកម្មភាពរបស់ខ្លួន។ |
| **មូលហេតុ៖** កំណត់សូចនាករផ្តោតលើលទ្ធផលចុងក្រោយ ជាជាងសូចនាករលទ្ធផល | |
| <**មធ្យោបាយផ្ទៀងផ្ទាត់**><br>1. បោះពុម្ពផ្សព្វផ្សាយ "គោលការណ៍ណែនាំស្តីពី WEE តាមរយៈការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ"<br>2. ផែនការពង្រីកយន្តការបញ្ជ្រាបយេនឌ័រ ត្រូវ បានដាក់បញ្ចូលទៅក្នុងផែនការប្រចាំឆ្នាំ ឬផែនការនារីរតនៈ(ផែនការរយៈពេល៥ឆ្នាំ) របស់ក្រសួងកិច្ចការនារី។ | <**មធ្យោបាយផ្ទៀងផ្ទាត់**><br>1. ផែនការប្រចាំឆ្នាំ និងឯកសារគម្រោងរបស់មន្ទីរដៃគូ<br>2. កំណត់ហេតុកិច្ចប្រជុំ និងរបាយការណ៍ គកសក<br>3. គោលការណ៍ណែនាំស្តីពី WEE បច្ចុប្បន្នកម្មដែលបានអនុម័ត<br>4. ផែនការតាមវិស័យ / ផែនការប្រចាំឆ្នាំ /ផែនការសកម្មភាពរបស់មន្ទីរដៃគូ និងសម្រាប់គោលនយោបាយយេនឌ័ររបស់ គជអប។ |
| **មូលហេតុ៖** បន្ថែមមធ្យោបាយផ្ទៀងផ្ទាត់ឱ្យស្របតាមសូចនាករ | |

(៦) លទ្ធផលរំពឹងទុកទី ១

| ពីមុន (ver.0) | កំណែថ្មី (ver.1) |
|---|---|
| **<សេចក្តីអធិប្បាយសង្ខេប>**<br>សមត្ថភាពរបស់ MOWA/PDWA ត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (WEE) នៅថ្នាក់ក្រោមជាតិតាមរយៈយន្តការបញ្ជ្រាបយេនឌ័រ។ | **<សេចក្តីអធិប្បាយសង្ខេប>**<br>សមត្ថភាពរបស់ MOWA/PDWA ក្នុងការស្វែងរកការគាំទ្រមតិ និងការសម្របសម្រួលត្រូវបានពង្រឹង យោងតាមលទ្ធផលនៃការវាយតម្លៃសមត្ថភាពផ្នែកយេនឌ័រ។ |
| **មូលហេតុ៖** បញ្ជាក់អំពីប្រភេទ ឬចំណុចដែលត្រូវពង្រឹងសមត្ថភាពបន្ថែមពីគម្រោង | |
| **<សូចនាករ>**<br>1-1 បណ្តាញអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ និងក្រោមជាតិត្រូវបានបង្កើតដើម្បីជំរុញ WEE តាមរយៈក្រុមការងារ TWGG-WEE។<br>1-2 'សៀវភៅសទ្ទានុក្រមយេនឌ័រ' ត្រូវបានធ្វើបច្ចុប្បន្នភាព។<br>1-3 "ខិត្តប័ណ្ណស្ថិតិយេនឌ័រ" ត្រូវបានធ្វើបច្ចុប្បន្នភាព ហើយសៀវភៅស្ថិតិយេនឌ័រថ្នាក់ខេត្តត្រូវបានរៀបចំនៅក្នុងខេត្តគោលដៅ។<br>1-4 គោលការណ៍ណែនាំស្តីពីវិធីសាស្ត្រ PGM ត្រូវបានកែសម្រួល និងបានដាក់បញ្ចូលការវិភាគខ្សែសង្វាក់តម្លៃដែលឆ្លើយតបនឹងយេនឌ័រ។<br>1-5 "គោលការណ៍ណែនាំស្តីពី WEE តាមរយៈការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ" ត្រូវបានបង្កើត។<br>1-6 ក្រសួង/មន្ទីរដៃគូពាក់ព័ន្ធ ដាក់បញ្ចូលសកម្មភាព និងយោបល់ដែលបានស្នើឡើងក្នុងអនុសាសន៍គោលនយោបាយ ក្រោមលទ្ធផលរំពឹងទុកទី ២ និងទី៣ ទៅក្នុងកម្មវិធី និងគម្រោងតាមរយៈការជំរុញលើកទឹកចិត្តពី MOWA/PDWA<br>1-7 ផែនការពង្រីកយន្តការបញ្ជ្រាបយេនឌ័រ សម្រាប់ WEE នៅថ្នាក់ក្រោមជាតិ ត្រូវបានបង្កើតដោយ MOWA សម្រាប់ធ្វើការអនុវត្តក្រៅពីខេត្តគោលដៅរបស់គម្រោងបន្ទាប់ពីគម្រោងត្រូវបានបញ្ចប់។ | **<សូចនាករ>**<br>1. សមត្ថភាពរបស់ MOWA/PDWA ក្នុងការស្វែងរកការគាំទ្រមតិ និងការសម្របសម្រួលត្រូវបានពង្រឹងយោងតាមលទ្ធផលនៃការវាយតម្លៃសមត្ថភាពផ្នែកយេនឌ័រ។ |
| **មូលហេតុ៖** កំណត់សូចនាករផ្តោតលើលទ្ធផលចុងក្រោយ ជាជាងសូចនាករលទ្ធផល | |
| **<មធ្យោបាយផ្ទៀងផ្ទាត់>**<br>1.1 កំណត់ហេតុកិច្ចប្រជុំ និងរបាយការណ៍របស់ក្រុមការងារ TWGG-WEE។<br>1.2 "សៀវភៅសទ្ទានុក្រមយេនឌ័រ" ដែលបានធ្វើបច្ចុប្បន្នភាព។<br>1.3 "ខិត្តប័ណ្ណស្ថិតិយេនឌ័រ" ដែលបានធ្វើបច្ចុប្បន្នភាព សៀវភៅស្ថិតិយេនឌ័រថ្នាក់ខេត្ត ដែលបានបង្កើត។ | **<មធ្យោបាយផ្ទៀងផ្ទាត់>**<br>1. លទ្ធផលនៃការប៉ាន់ប្រមាណសមត្ថភាពផ្នែកយេនឌ័រ<br>2. កំណត់ហេតុកិច្ចប្រជុំ និងរបាយការណ៍ក្រុមការងារបច្ចេកទេស TWG-G WEE / GMAG។<br>3. កំណត់ហេតុកិច្ចប្រជុំ និងរបាយការណ៍ក្រុមការងារ WEE / |

| | |
|---|---|
| 1.4 គោលការណ៍ណែនាំស្តីពីវិធីសាស្ត្រ PGM ដែលបានកែសម្រួល។<br>1.5 "គោលការណ៍ណែនាំ WEE តាមរយៈការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ" ដែលបានបង្កើត។<br>1.6 ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងផែនការប្រចាំឆ្នាំរបស់ក្រសួងដៃគូពាក់ព័ន្ធ ផែនការប្រចាំឆ្នាំរបស់ គកសក របស់ខេត្តគោលដៅ។<br>1.7 ផែនការពង្រីកយន្តការបញ្ជ្រាបយេនឌ័រ ដែលបានបង្កើត។ | គកសក។ |
| **មូលហេតុ៖** បន្ថែមមធ្យោបាយផ្ទៀងផ្ទាត់ឱ្យស្របតាមសូចនាករ | |

(៧) លទ្ធផលរំពឹងទុកទី ២

| ពីមុន **(ver.0)** | កំណែថ្មី **(ver.1)** |
|---|---|
| <**សេចក្តីអធិប្បាយសង្ខេប**><br>យន្តការបញ្ជ្រាបយេនឌ័រដែលបង្កើតឡើងដោយ PGM2 ត្រូវបានពង្រឹង ដើម្បីជំរុញការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (WEE) ជាមួយនឹងការតម្រង់ទិសទីផ្សារកសិកម្ម (ការចិញ្ចឹមមាន់) នៅថ្នាក់ក្រោមជាតិ ដើម្បីជាការត្រៀមក្នុងការពង្រីក និងផ្សព្វផ្សាយទូទាំងប្រទេស។ | <**សេចក្តីអធិប្បាយសង្ខេប**><br>តាមរយៈសកម្មភាពសាកល្បង យន្តការអនុវត្ត និងឧបករណ៍ដើម្បីលើកកម្ពស់ WEE ត្រូវបានពិនិត្យផ្ទៀងផ្ទាត់ថាមានប្រសិទ្ធភាព ដោយក្រសួងកិច្ចការនារី / មន្ទីរកិច្ចការនារីនិងក្រសួង / មន្ទីរដៃគូ។ |
| **មូលហេតុ៖** ដោយសារហេតុផលនៃការអនុវត្តសកម្មភាពក្នុងលទ្ធផលរំពឹងទុកទី ២ និងទី ៣ មានភាពដូចគ្នា<br>ដូចនេះគម្រោងគិតថាជាការសមស្របក្នុងការដាក់បញ្ចូលលទ្ធផលរំពឹងទុកទាំងពីរជាមួយគ្នាវិញ។ | |
| <**សូចនាករ**><br>2-1 ឧបករណ៍សម្រាប់ការពង្រីកសកម្មភាពកសិកម្ម (ការចិញ្ចឹមមាន់) ត្រូវបានរៀបចំផ្អែកតាមលទ្ធផលនៃការវិភាគផលប៉ះពាល់សេដ្ឋកិច្ច សង្គមកិច្ច ដែលឆ្លើយតបនឹង យេនឌ័ររបស់គម្រោង PGM2 និងការវិភាគខ្សែសង្វាក់តម្លៃ។<br>2-2 ការពង្រីកសកម្មភាព ត្រូវបានរៀបចំអនុវត្ត តាមដាន និងវាយតម្លៃ ដោយមន្ទីរកិច្ចការនារី និងមន្ទីរដៃគូ នៅក្នុងខេត្ត ៣ (កំពង់ឆ្នាំង កំពង់ធំ និងត្បូងឃ្មុំ) ដែលបានជ្រើសរើសតាមលក្ខណៈវិនិច្ឆ័យកំណត់ដោយ គកន។<br>2-3 ការពង្រីកសកម្មភាពត្រូវបានសម្របសម្រួល និងតាមដានដោយក្រុមការងារ WEE នៅក្នុងខេត្តគោលដៅ។<br>2-4 សកម្មភាពដែលពង្រីក ហើយជួយបង្កើនសមិទ្ធផល ត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយ និងផែនការសកម្មភាពរបស់ក្រសួង / មន្ទីរដៃគូពាក់ព័ន្ធ។ | <**សូចនាករ**><br>2-1 ឧបករណ៍ដើម្បីលើកកម្ពស់ WEE នៅថ្នាក់ក្រោមជាតិ ត្រូវបានសិក្សាដោយមន្ត្រីដៃគូក្រសួងកិច្ចការនារី មន្ទីរកិច្ចការនារី និងមន្ទីរដៃគូ។<br>2-2 តួនាទីរបស់ក្រុមការងារ WEE នៅក្នុងគម្រោងត្រូវបានដាក់បញ្ចូលក្នុងស្ថាប័ន និងនៅក្នុងគោលការណ៍ណែនាំស្តីពី WEE ដែលបានធ្វើបច្ចុប្បន្នភាព*។<br>* មុខងារ និងតួនាទីរបស់ក្រុមការងារ WEE ដែលបានកំណត់នៅក្នុងគោលការណែនាំស្តីពី WEE នឹងត្រូវបានដាក់បញ្ចូលទៅក្នុងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គកសក) តាមរយៈដំណើរការនៃការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធ។ |

<table>
<tr><td colspan="2">មូលហេតុ៖ កំណត់សូចនាករផ្តោតលើលទ្ធផលចុងក្រោយ ជាជាងសូចនាករសកម្មភាព</td></tr>
<tr><td><<b>សេចក្តីអធិប្បាយសង្ខេប</b> ><br>2-1 ឧបករណ៍ដែលបានបង្កើត (ដូចជាសៀវភៅក្បួនស្វែងរកទីផ្សារការចិញ្ចឹមមាន់)។<br>2-2 ផែនការសកម្មភាពរបស់ MOWA ដែលបានបង្កើត របាយការណ៍សិក្ខាសាលាស្តីពីវិធីសាស្ត្រ PGM ។<br>2-3 កំណត់ហេតុនៃកិច្ចប្រជុំ និងរបាយការណ៍របស់ក្រុមការងារ WEE ។<br>2-4 ផែនការប្រចាំឆ្នាំ និង/ឬ GMAPs របស់ក្រសួងដៃគូពាក់ព័ន្ធ ផែនការប្រចាំឆ្នាំរបស់ គកសក នៃខេត្តគោលដៅ។</td><td><<b>សេចក្តីអធិប្បាយសង្ខេប</b> ><br>1-1 កំណត់ត្រាការបណ្តុះបណ្តាល/សិក្ខាសាលា<br>1-2 កំណត់ហេតុកិច្ចប្រជុំ និងរបាយការណ៍ គកសក<br>2- គោលការណ៍ណែនាំស្តីពី WEE ដែលបានធ្វើបច្ចុប្បន្នភាព</td></tr>
<tr><td colspan="2">មូលហេតុ៖ បន្ថែមមធ្យោបាយផ្ទៀងផ្ទាត់ឱ្យស្របតាមសូចនាករ</td></tr>
</table>

(៨). លទ្ធផលរំពឹងទុកទី ៣

<table>
<tr><th>ពីមុន (ver.0)</th><th>កំណែថ្មី (ver.1)</th></tr>
<tr><td><<b>សេចក្តីអធិប្បាយសង្ខេប</b>><br>យន្តការបញ្ជ្រាបយេនឌ័រ ត្រូវបានបង្កើត ដើម្បីជំរុញការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (WEE) ក្នុងឧស្សាហកម្មទេសចរណ៍ជាមួយនឹងការតម្រង់ទិសទីផ្សារ នៅថ្នាក់ក្រោមជាតិ តាមរយៈការអនុវត្តគម្រោងសាកល្បង។</td><td><<b>សេចក្តីអធិប្បាយសង្ខេប</b>><br>អនុសាសន៍ (គោលគំនិតនិងមេរៀនទទួលបាន) ដើម្បី អនុវត្ត / រៀបចំគោលនយោបាយឱ្យឆ្លើយតបនឹងយេនឌ័រ ត្រូវបានទទួលស្គាល់ដោយក្រសួងនិងមន្ទីរដៃគូ និងក្រុមការងារយេនឌ័រនៃគជអប<br>តាមរយៈការពិភាក្សាយ៉ាងសកម្មជាមួយក្រសួងកិច្ចការនារី / មន្ទីរកិច្ចការនារី។</td></tr>
<tr><td colspan="2">មូលហេតុ៖ ដើម្បីលើកកម្ពស់ WEE នៅថ្នាក់ក្រោមជាតិ គោលគំនិតនិងមេរៀនដែលទទួលបានពីការអនុវត្តសកម្មភាពគម្រោង គួរត្រូវបានយកមកចែករំលែកនិងពិភាក្សាជាមួយក្រសួងដៃគូ។ គម្រោងក៏មានការរំពឹងថាគោលគំនិតនិងមេរៀនដែលទទួលបានខ្លះ អាចនឹងត្រូវបានយកទៅប្រើប្រាស់ឬដាក់បញ្ចូលទៅក្នុងគោលនយោបាយនិងផែនការតាមវិស័យ បន្ទាប់ពីគម្រោងត្រូវបានបញ្ចប់។</td></tr>
<tr><td><<b>សូចនាករ</b>><br>3-1 សកម្មភាពគម្រោងសាកល្បងត្រូវបានរៀបចំអនុវត្ត តាមដាន និងវាយតម្លៃដោយ PDWA និងមន្ទីរដៃគូនៅក្នុងខេត្តដែលបានជ្រើសរើស (សៀមរាប)។<br>3-2 បណ្តាញរវាងវិស័យសាធារណៈ និងឯកជនត្រូវបាន បង្កើតឡើងដើម្បីពង្រឹងទីផ្សារនៃគម្រោងសាកល្បង តាមរយៈក្រុមការងារ WEE។<br>3-3 លទ្ធផលនៃការសិក្សាស្រាវជ្រាវនានាអំពីទីផ្សារ ត្រូវបានចងក្រង ហើយឧបករណ៍សម្រាប់ពង្រឹងទីផ្សារគម្រោងសាកល្បងត្រូវបានបង្កើត។<br>3-4 ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចរបស់ស្ត្រីដែលចូលរួមនៅក្នុងឧស្សាហកម្មទេសចរណ៍មានភាពប្រសើរឡើង។ សូចនាករនឹងត្រូវសម្រេចដោយផ្អែកតាមការអង្កេតមូលដ្ឋាន ដែលរៀបចំដោយគម្រោង។<br>3-5 សកម្ម</td><td><<b>សូចនាករ</b>><br>3- អនុសាសន៍ (គោលគំនិតនិងមេរៀនទទួលបាន) ដើម្បីអនុវត្ត / រៀបចំគោលនយោបាយឲ្យឆ្លើយតបនឹងយេនឌ័រ ត្រូវបានទទួលស្គាល់ដោយក្រសួងនិងមន្ទីរដៃគូ និងក្រុមការងារយេនឌ័រនៃគជអប។</td></tr>
</table>

| | |
|---|---|
| ភាពដែលជួយបង្កើនសមិទ្ធិផលរបស់គម្រោង សាកល្បង ត្រូវបានដាក់បញ្ចូលទៅក្នុង គោលនយោបាយ និងផែនការសកម្មភាពរបស់ក្រសួង /មន្ទីរដៃគូពាក់ព័ន្ធ។ | |
| **មូលហេតុ៖** បន្ថែមមធ្យោបាយផ្ទៀងផ្ទាត់ឱ្យស្របតាមលទ្ធផលរំពឹងទុកទី ៣ | |
| <**មធ្យោបាយផ្ទៀងផ្ទាត់**><br>3-1 របាយការណ៍សិក្ខាសាលាស្ដីពីវិធីសាស្ត្រ PGM<br>3-2 កំណត់ហេតុនៃកិច្ចប្រជុំ និង របាយការណ៍របស់ក្រុមការងារ WEE។<br>3-3 របាយការណ៍នៃការស្រាវជ្រាវទីផ្សារ ឧបករណ៍ផ្សេងៗ ដែលបានបង្កើត<br>3-4 លទ្ធផលនៃការអង្កេតជាមូលដ្ឋាន និង ចុងបញ្ចប់<br>3-5 ផែនការប្រចាំឆ្នាំ និង/ឬ GMAPs របស់ក្រសួងដៃគូពាក់ព័ន្ធ ផែនការប្រចាំឆ្នាំរបស់ គកសក នៃខេត្តគោលដៅ។ | <**មធ្យោបាយផ្ទៀងផ្ទាត់**><br>១. កំណត់ហេតុកិច្ចប្រជុំ និងរបាយការណ៍ TWGG WEE/ GMAG / ក្រុមការងារយេនឌ័រ គជអប<br>២. កំណត់ហេតុកិច្ចប្រជុំ និងរបាយការណ៍របស់ គកសក |
| **មូលហេតុ៖** បន្ថែមមធ្យោបាយផ្ទៀងផ្ទាត់ឱ្យស្របតាមសូចនាករ | |

* ការកែសម្រួលសកម្មភាពមានបញ្ជាក់នៅក្នុង តារាងឧបសម្ព័ន្ធទី ៤-២។

២.៣.២. ខែមករា ឆ្នាំ២០២២ (សូមមើលឧបសម្ព័ន្ធទី ៣-៣)

(១). រយៈពេលអនុវត្តគម្រោង

| ពីមុន **(ver.1)** | កំណែថ្មី **(ver.2)** |
|---|---|
| ខែកុម្ភៈ ឆ្នាំ២០១៧ -ខែកុម្ភៈ ឆ្នាំ២០២២ | ខែកុម្ភៈ ឆ្នាំ២០១៧ -ខែធ្នូ ឆ្នាំ២០២២ |
| **មូលហេតុ៖** ដោយសារតែបញ្ហាកូវីដ-១៩ បានធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តសកម្មភាពក៏ដូចជាតារាងពេលវេលានៃការអនុវត្តសកម្មភាពគម្រោង។ សកម្មភាពសាកល្បងដូចជាការបង្កើនប្រាក់ចំណូល និងការតាមដានសម្រាប់ការបណ្តុះបណ្តាលជំនាញអាជីវកម្មនៅក្នុងលទ្ធផលរំពឹងទុកទី២ ត្រូវបានផ្អាកដំណើរ។ គម្រោងត្រូវបានបន្តរយៈពេល ១០ខែបន្ថែមទៀត ដោយយល់ឃើញថា ការអនុវត្តសកម្មភាពនៅមូលដ្ឋានគឺជាចំណុចសំខាន់ហើយចាំបាច់ ក្នុងការដកស្រង់យកបទពិសោធន៍ក៏ដូចជាការរៀនសូត្រ និងការវិភាគដើម្បីបង្កើតនូវគោលការណ៍ណែនាំរួមឈានទៅសម្រេចបាននូវគោលបំណងគម្រោង។ | |

(២). សកម្មភាព

| ពីមុន **(ver.1)** | កំណែថ្មី **(ver.2)** |
|---|---|
| 1.8 ការផ្តល់ប្រឹក្សាយោបល់ផ្នែកបច្ចេកទេស ស្តីពីការត្រួតពិនិត្យ និងវាយតម្លៃឆ្លើយតបនឹងយេនឌ័រ (ផ្អែកលើគោលនយោបាយ សម្រាប់តែផ្នែកដែលពាក់ព័ន្ធនឹង WEE តែប៉ុណ្ណោះ)ត្រូវបានផ្តល់ជូនទៅដល់ក្រសួងនិងមន្ទីរពាក់ព័ន្ធ ដែលជាដៃគូ ដោយក្រសួងកិច្ចការនារី /មន្ទីរកិច្ចការនារី តាមរយៈសកម្មភាពសាកល្បងនៅថ្នាក់ក្រោមជាតិ។ | 1.8 គោលគំនិតជាមូលដ្ឋាននៃការត្រួតពិនិត្យ និងវាយតម្លៃឆ្លើយតបនឹងយេនឌ័រ (ផ្អែកលើគោលនយោបាយ) ត្រូវបានចែករំលែកជាមួយនឹងក្រសួង និង មន្ទីរពាក់ព័ន្ធដែលជាដៃគូ ដោយក្រសួងកិច្ចការនារី / មន្ទីរកិច្ចការនារី។ |
| **មូលហេតុ៖**<br>មិនមែនគ្រប់ក្រសួងពាក់ព័ន្ធទាំងអស់សុទ្ធតែមានផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ (GMAP) ដែលមានសុពលភាពនោះទេ | |

| | |
|---|---|
| ដូច្នេះវាពិបាកក្នុងការផ្តល់យោបល់ផ្នែកបច្ចេកទេសលើការត្រួតពិនិត្យ និងការវាយតម្លៃដែលឆ្លើយតបនឹងយេនឌ័រដល់ក្រសួងទាំងនេះ។ ហេតុនេះ ទើបសម្រេចថា គោលគំនិតជាមូលដ្ឋាននៃការត្រួតពិនិត្យ និងការវាយតម្លៃឆ្លើយតបទៅនឹងយេនឌ័រ នឹងត្រូវចែករំលែកជាមួយក្រសួង និងមន្ទីរពាក់ព័ន្ធ តាមរយៈវគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំមួយចំនួនដើម្បីរិះរកវិធានការសមស្របក្នុងការរៀបចំធ្វើបច្ចុប្បន្នភាព GMAP ។ | |
| 1.9 វគ្គបណ្តុះបណ្តាលស្តីពី ការបញ្ជ្រាបយេនឌ័រ នឹងត្រូវបានរៀបចំនៅក្នុងប្រទេសជប៉ុន | លុបចោល |
| **មូលហេតុ៖** ដោយសារតែបញ្ហាកូវីដ-១៩ ធ្វើឱ្យអ្នកពាក់ព័ន្ធនៅក្រសួងកិច្ចការនារី / មន្ទីរកិច្ចការនារី មិនអាចទៅចូលរួមវគ្គបណ្តុះបណ្តាល ឬទស្សនៈកិច្ចនៅប្រទេសជប៉ុនបានទេ។ សកម្មភាពនេះត្រូវបានជំនួសមកវិញ គឺសិក្ខាសាលាចែករំលែកបទពិសោធន៍ (Retreat Program) រៀបចំនៅក្នុងប្រទេសកម្ពុជា ដើម្បីជាការពង្រឹងសមត្ថភាពក្រសួងកិច្ចការនារី / មន្ទីរកិច្ចការនារីក្នុងការស្វែងរកការគាំត្រមតិ និងការសម្របសម្រួលដើម្បីលើកកម្ពស់ WEE។ | |

២.៤. ផ្សេងៗ

២.៤.១. លទ្ធផលនៃការពិចារណាអំពីបរិស្ថាន និងសង្គម (ប្រសិនបើមាន)៖ មិនមាន

២.៤.២ លទ្ធផលនៃការពិចារណាទៅលើយេនឌ័រ / ការកសាងសន្តិភាព / ការកាត់បន្ថយភាពក្រីក្រ ពិការភាព ការឆ្លងមេរោគ/ជំងឺ ប្រព័ន្ធសង្គម សុខុមាលភាព សិទ្ធិមនុស្ស និងសមភាពយេនឌ័រ (ប្រសិនបើមាន)៖

- គម្រោងបានកំណត់នូវគោលគំនិត និងទស្សនទាន WEE មិនមែនមានតែនៅក្នុងទិដ្ឋភាពផ្នែកសេដ្ឋកិច្ច (ដូចជាប្រាក់ចំណូលមានការកើនឡើង និងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច) ប៉ុណ្ណោះទេ ប៉ុន្តែមាននៅក្នុងទិដ្ឋភាពផ្សេងៗទៀតនៃការរស់នៅរបស់ស្ត្រី។ ដូច្នេះហើយ លទ្ធផល និងផលប៉ះពាល់នៃសកម្ម ភាពសាកល្បងបានបង្ហាញឱ្យឃើញថា ទំនាក់ទំនងយេនឌ័រនៅក្នុងគ្រួសារមានការផ្លាស់ប្តូរ និងប្រសើរឡើងជាងមុន និងការពង្រឹងទំនុកចិត្តខ្លួនឯងដើម្បីរួមចំណែកកាត់បន្ថយចំនួនករណីអំពើហិង្សាក្នុង គ្រួសារ ព្រមទាំងការចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពសហគមន៍។ ក្នុងន័យនេះ គម្រោងបានរៀបចំ និងណែនាំនូវឧបករណ៍សម្រាប់អនុវត្តជាក់ស្តែង និងមានប្រសិទ្ធភាពដល់ការលើកកម្ពស់ភាពអង់អាចរបស់ស្ត្រី និងសមភាពយេនឌ័រនៅក្នុងផ្នែកនេះ។
- លទ្ធផលបានរកឃើញផងដែរថា សកម្មភាពបង្កើតប្រាក់ចំណូល និងអាជីវកម្មខ្នាតតូចរបស់ស្ត្រី ឬក្រុមស្ត្រី ដែលត្រូវបានគាំទ្រតាមរយៈសកម្មភាពសាកល្បង បានរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនៅក្នុងភូមិគោលដៅ។ស

III. លទ្ធផលនៃការត្រួតពិនិត្យរួមគ្នា

៣.១. លទ្ធផលនៃការត្រួតពិនិត្យដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ DAC នៃការវាយតម្លៃ

បន្ថែមពីលើលទ្ធផលនៃការវាយតម្លៃចុងក្រោយដែលធ្វើឡើងដោយទីប្រឹក្សាក្នុងស្រុក កាលពីខែសីហា ឆ្នាំ២០២២ បានរកឃើញបន្ថែមនូវចំណុច និងភស្តុតាងសំខាន់ៗមួយចំនួនទៀត។

៣.១.១. ភាពពាក់ព័ន្ធ៖ ខ្ពស់

**[ការអនុលោមតាមគោលនយោបាយជាតិ]**

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) (២០១៤-២០១៨) បានផ្តល់អាទិភាពដល់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងការធ្វើសេចក្តីសម្រេច។ NSDP (២០១៩-២០២៣) ក៏នៅតែបន្តរក្សានូវអាទិភាពទាំងនេះដែរ នេះមានន័យថា ចាប់ពីដំណាក់កាលបង្កើតរហូតដល់ដំណាក់កាលបញ្ចប់ គម្រោងនេះអនុលោមទៅតាមអាទិភាព ដែលមានចែងក្នុងគោលនយោបាយអភិវឌ្ឍន៍ជាតិកម្រិតខ្ពស់បំផុត ដូចជា NSDP។ ផ្អែកលើការត្រួតពិនិត្យប្រចាំឆ្នាំរបស់ NSDP ក្នុងឆ្នាំ២០១៩ និងក្រោយឆ្នាំ២០២៣ អាទិភាពទាំងពីរនេះត្រូវបានរំពឹងថានឹងនៅតែបន្តជាអាទិភាពយេនឌ័ររបស់រាជរដ្ឋាភិបាល

កម្ពុជា។

- នៅក្នុងគោលនយោបាយជាតិសមភាពយេនឌ័រ (២០២១-២០៣៥) ដែលកំពុងរៀបដាក់ឱ្យអនុវត្តមានចែង នូវយុទ្ធសាស្ត្រមួយដែលពាក់ព័ន្ធនឹងការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងជួររដ្ឋាភិបាល ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងបង្កើនភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធទាំងនេះ។ គោលនយោបាយនេះក៏បានចែងយ៉ាងច្បាស់ថា សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីគួរតែអាចសម្រេចបានតាមរយៈកំណើនសេដ្ឋកិច្ច និងកិច្ចគាំពារសង្គម។ គម្រោងនេះរួមចំណែកដល់ការសម្រេចបាននូវយុទ្ធសាស្ត្រទាំងនោះ ដោយប្រើប្រាស់នូវវិធីសាស្ត្រអនុវត្តជាក់ស្តែង និងមានប្រសិទ្ធភាព (ការពង្រឹងយន្តការបញ្ជ្រាបយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងបង្កើតឧបករណ៍សម្រាប់លើកកម្ពស់ WEE)។

**[ការអនុលោមតាមគោលនយោបាយតាមវិស័យ]**

- ផែនការនារីរតនៈទី ៤ (២០១៤-២០១៨) និងផែនការនារីរតនៈទី៥ (២០១៩-២០២៣) ផ្តោតលើយុទ្ធសាស្ត្រអាទិភាពចំនួនប្រាំមួយគឺៈ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ការលើកកម្ពស់ការអប់រំស្ត្រី និងក្មេងស្រី ការលើកកម្ពស់សុខភាពស្ត្រី និងក្មេងស្រី កិច្ចការការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី ស្ត្រីក្នុងវិស័យសាធារណៈ នយោបាយ ការសម្រេចចិត្ត និងភាពជាអ្នកដឹកនាំ និងការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីការប្រែប្រួលអាកាសធាតុ ដើម្បីលើកកម្ពស់សមភាពយេនឌ័រនៅកម្ពុជា។ ដូច្នេះ គម្រោងនេះត្រូវបានបង្កើតឡើងក្នុងនាមជាកម្មវិធីដ៏សំខាន់មួយរបស់នារីរតនៈ (ជាពិសេស ពាក់ព័ន្ធនឹងការលើកកម្ពស់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី) សម្រាប់ឆ្នាំ២០១៤-២០២៣។
- WEE ត្រូវបានចាត់ទុកថាជាលទ្ធផលមួយនៃក្របខ័ណ្ឌសូចនាករត្រួតពិនិត្យរួម នៃរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍ (JMIs ២០១៩-២០២៣)។ នៅក្នុងក្របខណ្ឌនេះ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍បានកំណត់សូចនាករចំនួនបីដូចខាងក្រោមៈ (ក).កម្មវិធីជាតិសម្រាប់ WEE (ខ).បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា (Cam-WEN) សម្រាប់លើកកម្ពស់ការបង្កើតបណ្តាញ ការចែករំលែកព័ត៌មាន និងការចែករំលែកចំណេះដឹងស្តីអំពីការអភិវឌ្ឍន៍សហគ្រិនភាពស្ត្រី យេនឌ័រ និងសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា អាស៊ាន និងពិភពលោក និង (គ).កម្មវិធីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច ដើម្បីសម្របសម្រួលភាគីពាក់ព័ន្ធដើម្បីសម្រេចគោលដៅ និងត្រួតពិនិត្យគោលដៅជាតិសម្រាប់លើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ គម្រោងនេះមានទំនាក់ទំនងយ៉ាងច្បាស់ជាមួយនឹងសូចនាករទីមួយដែលបានរៀបរាប់ខាងលើ។

**[ការអនុលោមតាមតម្រូវការជាក់ស្តែងនៃការអភិវឌ្ឍន៍]**

- អ្នកទទួលផលពីគម្រោង មានតាំងពីមន្ត្រីដៃគូ និងអ្នកពាក់ព័ន្ធក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាល រហូតដល់ស្ត្រីរស់នៅជនបទ និងក្រុមគ្រួសាររបស់ពួកគាត់ ដែលជាគោលដៅសំខាន់នៃកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់សមភាពយេនឌ័រ។
- ការបង្កើត និងប្រតិបត្តិការក្រុមការងារ WEE នៅថ្នាក់ក្រោមជាតិ មានប្រសិទ្ធភាពយ៉ាងខ្លាំងក្នុងការគាំទ្រដល់មន្ទីរដៃគូក្នុងខេត្តគោលដៅ ដើម្បីបញ្ជ្រាបយេនឌ័រសម្រាប់គាំទ្រដល់ស្ត្រីលើជំនាញរបស់ពួកគាត់ឱ្យកាន់តែមានប្រសិទ្ធភាព។
- ស្ត្រីក្រុមគោលដៅដែលបានជួបសម្ភាសន៍ ពួកគាត់បានសម្តែងនូវការដឹងគុណចំពោះក្រុមការងារ WEE ដែលបានផ្តល់នូវឱកាសដូចជា វគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេស និងអាជីវកម្ម វគ្គបណ្តុះ បណ្តាលយេនឌ័រ និងសកម្មភាពតាមដាន-ត្រួតពិនិត្យ។ ជាលទ្ធផលពួកគាត់មានអារម្មណ៍ និងសម្តែងជាលក្ខណៈបុគ្គលថា មានភាពអង់អាចផ្នែកផ្លូវចិត្ត និងសេដ្ឋកិច្ច ច្រើនជាងមុននៅក្នុងក្រុមគ្រួសារ និងនៅក្នុងសហគមន៍របស់ពួកគាត់។ ក្រុមគោលដៅជាច្រើនដែលកាលពីមុនធ្លាប់បានរងនូវអំពើហិង្សាក្នុងគ្រួសារ និងការបំបាក់ទឹកចិត្តពីសំណាក់ស្វាមី បានរាយការណ៍ថា គុណភាពជីវិតរបស់ពួកគាត់ប្រសើរឡើងយ៉ាងខ្លាំង ដោយសារបានទទួល និងអនុវត្តចំណេះដឹង និងជំនាញថ្មីៗតាមរយៈការចូលរួមនៅក្នុងគម្រោង។

**[វិធីសាស្ត្ររបស់គម្រោងមានភាពសមស្របក្នុងការបំពេញតម្រូវការអភិវឌ្ឍន៍]**

- PGM-WEE គឺជាដំណើរបន្តពីគម្រោងមុនៗ គឺគម្រោងបញ្ជ្រាបយេនឌ័រដំណាក់កាលទី១ (PGM1) និងដំណាក់កាលទី២ (PGM2) ដើម្បីបន្តពង្រឹងសមត្ថភាពរបស់ MOWA ក្នុងការបញ្ជ្រាបយេនឌ័រ តាម រយៈការអនុវត្តសកម្មភាពសាកល្បងក្នុងការដាក់បញ្ចូលទស្សនៈទានយេនឌ័រទៅក្នុងកិច្ចការគាំទ្ររបស់ រដ្ឋាភិបាលលើសកម្មភាពបង្កើតប្រាក់ចំណូល និង/ឬអាជីវកម្មខ្នាតតូចរបស់ស្ត្រីនៅជនបទ។ ផ្អែកលើបទពិសោធន៍នៃគម្រោងមុនៗ PGM-WEE បានកំណត់យ៉ាងច្បាស់ និងណែនាំបន្ថែមនូវគោលគំនិតស្តីពីការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅក្នុងគ្រប់ជំហាននៃវដ្តនៃការគ្រប់គ្រងគម្រោង។ គម្រោង PGM-WEE បានបង្កើតគោលការណ៍ណែនាំស្តីអំពី WEE ដែលជាឧបករណ៍អនុវត្តដ៏សំខាន់មួយ ដែលនឹងត្រូវធ្វើការរៀបចំនៅពេលបញ្ចប់គម្រោង។
- សមភាពយេនឌ័រគឺជាបញ្ហាអន្តរវិស័យ ដូច្នេះចាំបាច់ត្រូវមានវិធីសាស្ត្រពហុវិស័យដែលរួមបញ្ចូលជាមួយក្រសួង និងមន្ទីរពាក់ព័ន្ធ ព្រមទាំងអាជ្ញាធរខេត្ត ក្នុងការលើកកម្ពស់ WEE ក៏ដូចជាលើកកម្ពស់ជីវភាពរស់នៅ ដែលនឹងរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមជនបទ និងការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តរភាព។
- តាមរយៈបទពិសោធន៍របស់គម្រោងនេះ ការលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីកាន់តែមានប្រសិទ្ធភាព និងមានឥទ្ធិពលនៅពេលយើងក្រឡេកមើលទៅលើទស្សនៈចំនួនពីរស្របពេលតែមួយ គឺការបញ្ជ្រាបយេនឌ័រ និងស្ថានភាពសេដ្ឋកិច្ច។ ស្ថានភាពរបស់ស្ត្រីគោលដៅក្នុងខេត្តគោលដៅនីមួយៗ ត្រូវបានវិភាគជាប្រព័ន្ធដោយអនុវត្តវិធីសាស្ត្រដែលគម្រោងបានបង្កើត ទាំងនេះគឺជាចំណុចខ្លាំងរបស់គម្រោងពាក់ព័ន្ធទៅនឹងអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍ដើម្បីលើកកម្ពស់ WEE ដោយផ្អែកលើភស្តុតាងជាក់ស្តែង។

៣.១.២. ការផ្សារភ្ជាប់៖ ខ្ពស់

- ក្រោមកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា និងជប៉ុន PGM-WEE ត្រូវបានបង្កើតឡើងក្រោមក្របខណ្ឌ នៃគោលនយោបាយជំនួយរបស់ជប៉ុនសម្រាប់ប្រទេសកម្ពុជា (ខែកក្កដា ឆ្នាំ២០១៧) ដែលជាឯកសារ គ្របដណ្តប់នៅកម្រិតថ្នាក់ជាតិរបស់ប្រទេសជាដៃគូសម្រាប់ជំនួយអភិវឌ្ឍន៍ក្រៅប្រទេស (ODA) របស់ជប៉ុន។ នៅក្នុងគោលនយោបាយនេះ ការបញ្ជ្រាបយេនឌ័រគឺជាផ្នែកមួយដែលមិនអាចខ្វះបាននៃអភិបាលកិច្ច ដើម្បីទទួលបាននូវសង្គមមួយដែលប្រកបដោយនិរន្តរភាព។ នៅក្នុងដំណាក់កាលបង្កើតគម្រោង ក្រុមការងារ ODA បានកត់សម្គាល់ពីទស្សនៈរបស់ប្រទេសជប៉ុនចំពោះការគាំទ្រដល់ស្ត្រី និងសន្តិសុខមនុស្សជាតិ និងយល់ឃើញថា នៅកម្ពុជា ទោះបីជាមានការតស៊ូមតិលើសមភាពយេនឌ័រ និងការកែលម្អស្ថានភាពរបស់ស្ត្រីក្នុងគោលនយោបាយកម្រិតខ្ពស់ក៏ដោយ ក៏មិនទាន់ឃើញមានការរីកចម្រើនគួរឱ្យកត់សម្គាល់នៅក្នុងសង្គមដែរ។ PGM-WEE នឹងផ្តោតលើការកសាងយន្តការមួយដើម្បីបញ្ជ្រាបយេនឌ័រនៅក្នុងសកម្មភាពបង្កើតប្រាក់ចំណូលសម្រាប់ស្ត្រីនៅតាមជនបទ តាមរយៈការពង្រឹងសមត្ថភាពរបស់ MOWA និង PDWA ដើម្បីសម្របសម្រួលវេទិកាបែបនេះប្រកបដោយប្រសិទ្ធភាព។
- MOWA បានទទួលស្គាល់ថាគម្រោង PGM-WEE គឺជាផ្នែកនៃកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព SDG-5 គឺសមភាពយេនឌ័រ ហើយគម្រោងនេះត្រូវបានអនុម័តដោយ JICA ផងដែរ។ ក្រៅពីនេះ គម្រោងនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ SDGs ផ្សេងទៀត ដូចជាការកាត់បន្ថយភាពក្រីក្រ ការលុបបំបាត់ភាពអត់ឃ្លាន ការអប់រំ និងសុខភាពនៅកម្ពុជា។

៣.១.៣. ប្រសិទ្ធភាព៖ ខ្ពស់បង្គួរ

- ក្នុងអំឡុងពេលអនុវត្តគម្រោង គម្រោងបានបញ្ចប់រាល់សកម្មភាពដែលបានគ្រោងទុក លើកលែងតែសិក្ខាសាលាថ្នាក់តំបន់ (សកម្មភាព៣-៧) ដែលត្រូវបានកែប្រែទៅជាសិក្ខាសាលាចែករំលែកបទពិសោធន៍ (លទ្ធផលរំពឹងទុក) (សកម្មភាព ៣-៦) ដោយផ្អែកលើកិច្ចព្រមព្រៀងដែលបានធ្វើឡើងនៅក្នុង JCC លើកទី៤ នៅខែសីហាឆ្នាំ ២០២២។
- សកម្មភាពគម្រោងមានលទ្ធភាពខ្ពស់ក្នុងការសម្រេចបាននូវគោលបំណង

គម្រោងដែលបានកំណត់ក្នុង តារាង PDM ហើយចំណុចសំខាន់ៗមួយចំនួនមានបង្ហាញដូចខាងក្រោមៈ

- សមត្ថភាពរបស់ MOWA និង PDWA ក្នុងការស្វែងរកការគាំត្រមិត និងការសម្របសម្រួលដើម្បីបញ្ជ្រាបទស្សនទានយេនឌ័រ និង WEE មានភាពប្រសើរឡើងខ្ពស់តាមរយៈការអនុវត្តសកម្មភាពសាកល្បង និងសិក្ខាសាលាបញ្ជ្រាបយេនឌ័រនៅតាមខេត្តនីមួយៗ ក៏ដូចជាកម្មវិធីសិក្ខាសាលាចែករំលែកបទពិសោធន៍ (retreat program) ដែលធ្វើឡើងក្នុងខែកក្កដា ឆ្នាំ២០២២។ ជាលទ្ធផល PDWA និងមន្ទីរមួយចំនួនបានចាប់ផ្តើមពិភាក្សា និងសម្របសម្រួលលើកិច្ចការដាក់បញ្ចូលទស្សនទានយេនឌ័រ ឬ WEE ទៅក្នុងគម្រោង ឬសកម្មភាពដែលមានស្រាប់ (ឧទាហរណ៍ៈ គម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច (AIMS) និងកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) ដែលគាំទ្រដោយ IFAD /MOAF និងគម្រោងភូមិមួយផលិតផលមួយ (OVOP) របស់ PDISTI។
- នៅក្នុងខេត្តគោលដៅនីមួយៗ WEE-WG ត្រូវបានបង្កើតឡើងជាវេទិកាដែលជួយសម្រួលដល់ការសម្របសម្រួល និងចែករំលែកបទពិសោធន៍ដល់មន្ទីរពាក់ព័ន្ធសម្រាប់ការធ្វើផែនការ អនុវត្ត និងត្រួតពិនិត្យសកម្មភាពសាកល្បង (សកម្មភាពពាក់ព័ន្ធនឹង WEE)។ តាមរយៈសកម្មភាពរបស់ WEE-WG គំរូកិច្ចសហប្រតិបត្តិការថ្នាក់ខេត្តមួយត្រូវបានបង្កើតឡើង ដែលជំរុញឱ្យមានការចូលរួមយ៉ាងផុសផុលពីមន្ទីរដៃគូ។ នៅចុងបញ្ចប់នៃគម្រោង ខេត្តនីមួយៗបានពិភាក្សាអំពីការរៀបចំមុខងារ និងរចនាសម្ព័ន្ធរបស់ក្រុមការងារ WEE និងបានសម្រេចដាក់នៅក្រោម គកសក គឺមានខេត្តកំពង់ចាម កំពង់ឆ្នាំង កំពង់ធំ និងត្បូងឃ្មុំ ចំណែកឯខេត្តសៀមរាប គឺដាក់នៅក្រោមរដ្ឋបាលខេត្ត ដោយមានការយល់ស្របពីឯកឧត្តមអភិបាលខេត្ត។ ទាំងនេះបង្ហាញពីប្រសិទ្ធភាពនៃវិធីសាស្ត្រគម្រោងតាមរយៈក្រុមការងារ WEE ។
- នៅថ្នាក់ជាតិ គម្រោងនេះលើកកម្ពស់ការពិភាក្សាអំពីការត្រួតពិនិត្យឆ្លើយតបនឹងយេនឌ័រតាមរយៈទស្សនទាន WEE និងការចាត់ចែងថវិកាដែលឆ្លើយតបនឹងយេនឌ័រតាមរយៈកិច្ចសន្ទនាជាមួយ ក្រុមការងារ GMAGs។ គម្រោងក៏បានពិភាក្សាជាបន្តបន្ទាប់ ជាមួយក្រុមគោលនយោបាយយេនឌ័រ របស់ គ.ជ.អ.ប. អំពីការប្រើប្រាស់លទ្ធផលនិងបទពិសោធន៍ដែលទទួលបានពីសកម្មភាពសាកល្បងនៅថ្នាក់ខេត្ត ក្នុងការអនុវត្តផែនការសកម្មភាពនៃគោលនយោបាយយេនឌ័ររបស់ គ.ជ.អ.ប។ ក្រៅពីនេះ MOWA បានអញ្ជើញសមាជិក GMAG ឱ្យចូលរួមក្នុងសកម្មភាពជាច្រើនដែលនៅក្រោមគម្រោង PGM-WEE ដើម្បីចែករំលែកអំពីលទ្ធផល និងបទពិសោធន៍នៃការធ្វើផែនការ និងការអនុវត្តគម្រោងដែលឆ្លើយតបនឹងយេនឌ័រ។ ជាលទ្ធផល គម្រោង ឬកម្មវិធីដែលឆ្លើយតបនឹងយេនឌ័រ ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការតាមវិស័យទាំងនៅថ្នាក់ជាតិតាមរយៈ GMAGs និងនៅថ្នាក់ខេត្តតាមរយៈមន្ទីរដៃគូក្នុងខេត្តគោលដៅ។

• ក្រុមការងារ WEE ត្រូវបានទទួលស្គាល់ថាជាឧបករណ៍សហការដ៏មានប្រសិទ្ធភាពក្នុងការលើកកម្ពស់ WEE នៅថ្នាក់ខេត្ត ដោយមន្ទីរកិច្ចការនារី និងមន្ទីរដៃគូដែលគ្របដណ្តប់លើវិស័យកសិកម្ម ទេសចរណ៍ ពាណិជ្ជកម្ម ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អភិវឌ្ឍន៍ជនបទ ឧស្សាហកម្ម និងការធ្វើផែនការតាមមូលដ្ឋាន។ វាបានបង្ហាញថា ទិសដៅរួមនៃការបញ្ជ្រាបយេនឌ័រ និងការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី នឹងក្លាយជាជំហានដ៏សំខាន់មួយដើម្បីឆ្ពោះទៅរកការកាត់បន្ថយវិសមភាពយេនឌ័រ តាមរយៈការពង្រឹងសមត្ថភាពស្ត្រីក្នុងការបង្កើតប្រាក់ចំណូល បង្កើនការគោរពខ្លួនឯង និងភាពសុខដុមក្នុងគ្រួសារ និងកាត់បន្ថយអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ និងភាពក្រីក្រ។ ក្រុមការងារ WEE អាចត្រូវបានពង្រីក និងបើកទូលាយស្វាគមន៍ការចូលរួមរបស់មន្ទីរផ្សេងទៀត និង/ឬវិស័យផ្សេងៗនៅក្រោមមន្ទីរដដែលផងដែរ។

៣.១.៤. ប្រសិទ្ធផលៈ មធ្យម

- ការចំណាយពេលវេលាបន្ថែមសម្រាប់ការកសាងសមត្ថភាពរបស់ MOWA និង PDWA (លទ្ធផលរំពឹងទុកទី១) និងការអនុវត្តសកម្មភាពសាកល្បង (លទ្ធផលរំពឹងទុកទី២) បណ្តាលឱ្យនៅសល់ពេលវេលាតិចតួចសម្រាប់បញ្ចប់សកម្មភាពក្រោមលទ្ធផលរំពឹងទុកទី៣។ ដើម្បីបង្កើនប្រសិទ្ធផល ចាំបាច់ត្រូវមានការកសាងសមត្ថភាពបន្ថែមសម្រាប់ MOWA និង PDWA ក្នុងការអនុវត្តសកម្មភាពសាកល្បង តាម រយៈការផ្តល់ជំនួយបច្ចេកទេសបន្ថែមលើចំណេះដឹង និងជំនាញចាំបាច់ក្នុងការតស៊ូមតិ និងការសម្របសម្រួលការបញ្ជ្រាបយេនឌ័រ។
- ដោយសារការរីតបន្តឹងការធ្វើដំណើរក្នុងអំឡុងពេលកូវីដ-១៩ សកម្មភាពសាកល្បងភាគច្រើននៅតាមភូមិត្រូវបានផ្អាកអស់មួយរយៈពេល។ ទោះជាយ៉ាងណាក៏ដោយ សមាជិក WEE-WG បានបន្តធ្វើកិច្ចការរៀបចំ និងប្រជុំបច្ចេកទេសជាបន្តបន្ទាប់ តាមប្រព័ន្ធអនឡាញ ដូច្នេះសកម្មភាពសាកល្បងអាចចាប់ផ្តើមឡើងវិញភ្លាមៗបន្ទាប់ពីមានការបើកឱ្យធ្វើដំណើរវិញ។
- ដើម្បីបំពេញឡើងវិញនូវការផ្អាក និងភាពយឺតយ៉ាវក្នុងអំឡុងពេលកូវីដ-១៩ គម្រោងត្រូវបានពន្យារពេលរហូតដល់ទៅ ១០ខែ។ ទោះជាយ៉ាងនេះក្តី ក៏គម្រោងនៅតែមានការពិបាកក្នុងការបើកវគ្គបណ្តុះ បណ្តាលនៅតាមភូមិតាមការគ្រោងទុក។ ប៉ុន្តែវគ្គបណ្តុះបណ្តាលនៅតែបានធ្វើឡើង ដោយបានកាត់ខ្លឹមសារ ឬរួមបញ្ចូលគ្នាជាមួយប្រធានបទផ្សេងដើម្បីសន្សំពេលវេលា។ ជាលទ្ធផល ស្ត្រីគោលដៅជួបប្រទះការលំបាកក្នុងការយល់ច្បាស់អំពីប្រធានបទមួយចំនួន ដោយសារតែការពន្យល់មានល្បឿនលឿន និងពេលវេលាមានកំណត់។ ប្រធានបទទាំងនោះត្រូវបានបង្រៀនម្តងទៀតនៅក្នុងវគ្គរំលឹក។
- ចំពោះធាតុចូល ជំនាញការជប៉ុនដែលមានជំនាញពាក់ព័ន្ធត្រូវបានចាត់តាំងដើម្បីលើកកម្ពស់ការអនុវត្តតួនាទីប្រកបដោយប្រសិទ្ធភាព។ ចំនួនមន្ត្រីដៃគូ (C/Ps) ចាំបាច់ត្រូវបានបែងចែកសម្រាប់ការអនុវត្តសកម្មភាពសាកល្បងនៅថ្នាក់ខេត្ត។ រយៈពេលបំពេញការងាររបស់ជំនាញការម្នាក់ៗ មានភាពគ្រប់គ្រាន់ និងសមស្រប។ លក្ខណៈបច្ចេកទេស និងគុណភាពនៃបរិក្ខា ដែលគម្រោងបានផ្តល់ជូនគឺពាក់ព័ន្ធសម្រាប់ការអនុវត្តសកម្មភាព និងបានចែកចាយដោយសមធម៌រវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

៣.១.៥. ផលប៉ះពាល់ៈ កម្រិតមធ្យម

ការវាស់វែងទៅលើផលប៉ះពាល់របស់គម្រោង អាចធ្វើឡើងបានត្រឹមត្រូវគឺក្នុងអំឡុងពេល ៣ទៅ៥ឆ្នាំ ក្រោយបន្ទាប់ពីគម្រោងបញ្ចប់ រួមជាមួយនឹងការវាយតម្លៃលើការសម្រេចបាននូវគោលដៅរួមរបស់គម្រោងផងដែរ។ ទោះជាយ៉ាងនេះក្តី ឥទ្ធិពលវិជ្ជមានជាប្រព័ន្ធទៅលើមន្ត្រីដៃគូ (C/Ps) ក្រសួង និងមន្ទីរដៃគូ និងស្ត្រីគោលដៅ និងក្រុមគ្រួសាររបស់ពួកគាត់អាចត្រូវបានពិពណ៌នាដូចខាងក្រោមៈ

- សង្កេតឃើញថាមានផលប៉ះពាល់ខ្លាំងទៅលើការទទួលបានចំណេះដឹង និងជំនាញបញ្ជ្រាបយេនឌ័រនៅក្នុងការគ្រប់គ្រងវដ្តនៃគម្រោងរបស់មន្ត្រីដៃគូ និងអ្នកពាក់ព័ន្ធដែលចូលរួមក្នុងគម្រោង ជាពិសេសនៅក្នុង MOWA, PDWA, សមាជិកក្រុមការងារ WEE និងក្រសួងពាក់ព័ន្ធ។ ជាលទ្ធផលនៃការចូលរួមសកម្មភាពគម្រោង MOWA និង PDWA បានបង្ហាញពីកំណើននៃភាពជឿជាក់ និងទំនុកចិត្តរបស់ខ្លួនក្នុងការលើកកម្ពស់ការបញ្ជ្រាបយេនឌ័រ និង WEE។ អ្នកចូលរួមមកពីក្រសួង និងមន្ទីរពាក់ព័ន្ធពេញចិត្តជាខ្លាំងចំពោះកិច្ចសហការតាមរយៈក្រុមការងារ WEE និងបានរៀនសូត្រពីអត្ថប្រយោជន៍នៃសកម្ម ភាព WEE ដែលឆ្លើយតបនឹងយេនឌ័រ។
- ផលប៉ះពាល់ជាវិជ្ជមាន និងការផ្លាស់ប្តូរជាច្រើនទៅលើស្ត្រីគោលដៅ និងទំនាក់ទំនងយេនឌ័រនៅក្នុងក្រុមគោលដៅពាក់ព័ន្ធនឹងធាតុទាំង៦របស់ WEE ត្រូវបានពង្រឹងតាមរយៈការបណ្តុះបណ្តាលយេនឌ័រ (ឱកាសក្នុងការចូលរួមក្នុងវគ្គបណ្តុះបណ្តាល ការចែករំលែកព័ត៌មាន ការបែងចែកការងារនិងការទទួលខុសត្រូវ ការគ្រប់គ្រង និងចាត់ចែងប្រាក់ចំណូល ការធ្វើសេចក្តីសម្រេចចិត្ត ក៏ដូចជាការគោរពខ្លួនឯង និងការទទួលស្គាល់ពីអ្នកដទៃ)។ ចំនួននៃឧប្បត្តិហេតុនៃអំពើហិង្សាក្នុងគ្រួសារនៅក្នុងភូមិគោលដៅបានថយចុះជាច្រើន ក្រោយពីសកម្មភាពគម្រោងបានចាប់ផ្តើម។

- ពាក់ព័ន្ធនឹងការសម្រេចបាននូវគោលដៅរួម ចាំបាច់ត្រូវមានការលើកកម្ពស់ WEE បន្ថែមទៀតតាម រយៈការធ្វើផែនការ និងការអនុវត្តគម្រោង និងកម្មវិធីដែលឆ្លើយតបនឹងយេនឌ័រ។ តាមរយៈផលប៉ះពាល់របស់គម្រោង ក្រសួង និងមន្ទីរពាក់ព័ន្ធមានចេតនាសហការកាន់តែច្រើន ដើម្បីលើកកម្ពស់ WEE។ មានការរំពឹងថា MOWA នឹងមិនត្រឹមតែបន្តការស្វែងរកការគាំទ្រមតិ និងការសម្របសម្រួលនៅក្នុងខេត្តគោលដៅប៉ុណ្ណោះទេ ប៉ុន្តែក៏នឹងពង្រីកទៅកាន់ខេត្តដែលមិនមែនជាគោលដៅផ្សេងទៀតផងដែរ ក្នុងកិច្ចសហការជាមួយក្រសួងដៃគូ។

៣.១.៦. និរន្តរភាពៈ មធ្យម

- និរន្តរភាពគោលនយោបាយមានកម្រិតខ្ពស់ ដោយសារតែអាទិភាពដ៏រឹងមាំរបស់ WEE បន្តមាននៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ និងអាណត្តិរបស់ MOWA ។ អាចសន្និដ្ឋានបានថា សកម្មភាព និងលទ្ធផលគម្រោង នៅតែជាប់ពាក់ព័ន្ធទៅនឹងអាទិភាពគោលនយោបាយក្នុងការលើកកម្ពស់ WEE ជាពិសេសនៅតំបន់ជនបទ ដែលរួមចំណែកដល់ការសម្រេចតាមសូចនាករអភិវឌ្ឍន៍ដែលពាក់ព័ន្ធ (ឧ. សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ និងសន្ទស្សន៍វិសមភាពយេនឌ័រ) និងគោលដៅ SDG-5 និងគោលដៅពាក់ព័ន្ធផ្សេងទៀតដែលត្រូវសម្រេចបាននៅ ឆ្នាំ២០៣០។
- និរន្តរភាពស្ថាប័នមានកម្រិតមធ្យម ដោយសារខេត្តគោលដៅទាំងប្រាំបានសម្រេចចិត្តធ្វើការរៀបចំ មុខងារ និងការទទួលខុសត្រូវរបស់ក្រុមការងារ WEE ក្រោមរចនាសម្ព័ន្ធរបស់ គកសក ឬរដ្ឋបាលខេត្ត ដោយមានការយល់ព្រមពីឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត។ នេះគឺជាវេទិកាដ៏សំខាន់មួយសម្រាប់ការបញ្ជ្រាបយេនឌ័រ និងការលើកកម្ពស់ WEE នៅថ្នាក់ខេត្ត។ លើសពីនេះទៀត អនុក្រុមការងារ TWG-G ស្តីពី WEE ត្រូវបានកោះប្រជុំក្នុងខែតុលា ឆ្នាំ២០២២ និងបានព្រមព្រៀងដើរតួជាវេទិកាថ្នាក់ជាតិសម្រាប់ការចែករំលែកព័ត៌មាន និងការសម្របសម្រួលគម្រោង និងសកម្មភាពលើកកម្ពស់ WEE។ មានការរំពឹងទុកខ្ពស់ថា ខេត្តគោលដៅនឹងបន្តកិច្ចខិតខំប្រឹងប្រែងត្រួតពិនិត្យតាមដានសកម្មភាពគម្រោង PGM-WEE ដើម្បីលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅកម្រិតជនបទ និងផ្តល់ជំនួយផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុចាំបាច់។
- និរន្តរភាពផ្នែកបច្ចេកទេស និងធនធានមនុស្សមានកម្រិតមធ្យម ទោះបីជាចំណេះដឹង និងជំនាញចាំបាច់ សម្រាប់ការលើកកម្ពស់ WEE ត្រូវបានចងក្រងនៅក្នុងគោលការណ៍ណែនាំអំពី WEE និងមានការពង្រឹងសមត្ថភាពរបស់ MOWA និង PDWA ដូចដែលមានបញ្ជាក់ឡើងតាមរយៈការវាយតម្លៃក៏ដោយ ចាំបាច់ត្រូវពិចារណាពីរបៀបទាញយកអត្ថប្រយោជន៍ពីធនធានបច្ចេកទេស និងធនធានមនុស្សនៅក្នុង MOWA ដែលទទួលបានការពង្រឹងសមត្ថភាពដោយ PGM-WEE ក្នុងកិច្ចការស្វែងរកការគាំទ្រមតិ និង ការសម្របសម្រួលឱ្យកាន់តែមានប្រសិទ្ធភាពជាមួយក្រសួងពាក់ព័ន្ធ ដើម្បីបង្កើនការបញ្ជ្រាបយេនឌ័រ។
- និយាយពីថវិកាជារួមសម្រាប់ MOWA និរន្តរភាពហិរញ្ញវត្ថុមានកម្រិតមធ្យម ដោយសារ WEE ស្ថិតក្នុងលំដាប់ទាបនៅក្នុងបញ្ជីអាទិភាពរបស់រាជរដ្ឋាភិបាល។ វាជាកិច្ចចាំបាច់ដែល MOWA គួរចរចាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបែងចែកថវិកាសម្រាប់សកម្មភាពពាក់ព័ន្ធនឹងការផ្សព្វផ្សាយ WEE នៅថ្នាក់ខេត្ត។ ជាងនេះទៅទៀត តួនាទីរបស់អនុក្រុមការងារ WEE នៃ TWG-G អំពីការលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនឹងកាន់តែមានប្រសិទ្ធភាពក្នុងការសម្របសម្រួលការបែងចែកធន ធានសម្រាប់លើកកម្ពស់ WEE ជាពិសេសនៅតំបន់ជនបទ។ស

៣.២. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ការអនុវត្ត និងលទ្ធផលគម្រោង

មុនពេលការចាប់ផ្តើមគម្រោង ពុំទាន់មានគោលការណ៍ជាក់លាក់ណាមួយសម្រាប់ការលើកកម្ពស់ការបញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការនោះទេ។ ទោះជាយ៉ាងណាក៏ដោយ គោលនយោបាយថ្មីរបស់គណៈ

កម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ស្តីពីការលើកកម្ពស់សមភាពយេនឌ័រសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានអនុម័តនៅក្នុងខែឧសភា ឆ្នាំ២០១៩។

៣.៣. លទ្ធផលនៃការវាយតម្លៃទៅលើការគ្រប់គ្រងហានិភ័យគម្រោង

(១) លទ្ធផលនៃការគ្រប់គ្រងហានិភ័យ

ពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យដែលបានលើកឡើងនៅក្នុងផ្នែកទី២ ក្រសួងកិច្ចការនារី និង JICA បានព្រមព្រៀងគ្នានៅក្នុងបេសកកម្មក្រុមប្រឹក្សាយោបល់កាលពីខែកក្កដា ឆ្នាំ២០១៧ ថានឹងរៀបចំសារឡើងវិញនូវក្របខ័ណ្ឌគម្រោង គោលដៅ លទ្ធផលរំពឹងទុក និងសកម្មភាពក្នុងទិសដៅធ្វើយ៉ាងណាឱ្យសកម្មភាពនៅលើមូលដ្ឋានអនុលោមទៅតាមគោលនយោបាយថ្មីរបស់ គ.ជ.អ.ប។ បន្ទាប់ពីកិច្ចពិភាក្សានៅក្នុងបេសកកម្ម របស់ក្រុមប្រឹក្សាយោបល់ដែលបានបញ្ជូនមកពីទីស្នាក់ការកណ្តាលរបស់អង្គការ JICA ក្នុងខែកក្កដា ឆ្នាំ២០១៨ និងបេសកកម្មត្រួតពិនិត្យពាក់កណ្តាលអាណត្តិក្នុង ខែកញ្ញា ឆ្នាំ២០១៨ តារាង PDM ត្រូវបានអនុម័តជាផ្លូវការឱ្យកែសម្រួលនៅក្នុងកិច្ចប្រជុំ JCC លើកទី៣ ក្នុងខែធ្នូ ឆ្នាំ២០១៨។

(២) លទ្ធផលនៃការប្រើប្រាស់បទពិសោធន៍របស់គម្រោងពាក់ព័ន្ធ

- ស្រដៀងទៅនឹងគម្រោង PGM2 ដែរ ភាពសកម្មរបស់ថ្នាក់ដឹកនាំស្ត្រីនៅក្នុងជួររដ្ឋាភិបាលថ្នាក់ក្រោម ជាតិ ដូចជា អភិបាលរងខេត្ត និងប្រធាន WCCC បានរួមចំណែកដល់ការអនុវត្តសកម្មភាពសាកល្បងដោយរលូន។ ករណីនេះក៏បានរួមចំណែកដោយជោគជ័យក្នុងការជំរុញភាពជាម្ចាស់នៃមន្ទីរពាក់ព័ន្ធ ផងដែរ។ ការប្តេជ្ញាចិត្តដ៏ពេញលេញរបស់ពួកគាត់លើសកម្មភាពគម្រោង និងការយល់ដឹងស៊ីជម្រៅអំពីប្រសិទ្ធភាពនៃឧបករណ៍ និងយន្តការដែលគម្រោងបានបង្កើតឡើង គឺមិនអាចខ្វះបានឡើយក្នុងការសម្រេចបាននូវលទ្ធផលរំពឹងទុកទី២ (សូចនាករ ២-២) និងគោលបំណងគម្រោង (សូចនាករទី២) ។
- ដោយពិចារណាលើសារៈសំខាន់នៃទីផ្សារ និងការគាំទ្រផ្នែកអាជីវកម្មសម្រាប់ស្ត្រីនៅជនបទ និងអាជីវកម្ម ខ្នាតតូចរបស់ស្ត្រី ក៏ដូចជាការភ្ជាប់បណ្តាញជាមួយវិស័យឯកជន គម្រោងនេះបានបង្កើតកញ្ចប់បណ្តុះ បណ្តាលអាជីវកម្ម សម្រាប់ស្ត្រីនៅជនបទ រួមទាំងផ្នែកទីផ្សារ និងការគ្រប់គ្រងអាជីវកម្មផងដែរ។ លើសពីនេះទៀត ឧបករណ៍វិភាគខ្សែច្រវ៉ាក់តម្លៃដែលឆ្លើយតបនឹងយេនឌ័រត្រូវបានបង្កើតឡើងសម្រាប់ស្វែងយល់អំពីបញ្ហាឬឧបសគ្គដែលស្ត្រីជួបប្រទះឬប្រឈមក្នុងការប្រកបអាជីវកម្មរបស់ពួកគាត់។ សកម្មភាព សាកល្បងសម្រាប់ការផ្សព្វផ្សាយទេសចរណ៍នៅក្នុងខេត្តសៀមរាប ក៏បានលើកកម្ពស់ការផ្សព្វផ្សាយឱ្យមានការបង្កើតបណ្តាញជាមួយវិស័យឯកជនផងដែរ។

៣.៤. មេរៀន និងបទពិសោធន៍ដែលទទួលបាន

- យុទ្ធសាស្ត្រអន្តរវិស័យសម្រាប់ការលើកកម្ពស់ WEE មានប្រសិទ្ធភាពក្នុងការបង្កើតលទ្ធផលជាក់ស្តែងទាក់ទងនឹងការកើនឡើងនៃប្រាក់ចំណូល និងការពង្រឹងភាពអង់អាចរបស់ស្ត្រីដោយប្រើប្រាស់ជំនាញ និងចំណេះដឹងដែលមានស្រាប់របស់មន្ទីរពាក់ព័ន្ធ ។
- ឧបករណ៍អនុវត្តដែលត្រូវបានបង្កើតឡើង និងផ្តល់សក្ខីកម្មតាមរយៈសកម្មភាពសាកល្បងនៅក្នុង PGM-WEE គឺជាគន្លឹះដ៏មានប្រយោជន៍យ៉ាងសំខាន់លើ "ការគ្រប់គ្រងវដ្តនៃគម្រោងឆ្លើយតបយេនឌ័រ" សម្រាប់ការលើកកម្ពស់មិនត្រឹមតែ WEE ប៉ុណ្ណោះទេ ថែមទាំងការបញ្ជ្រាបយេនឌ័រជាទូទៅផងដែរ។
- ប្រធានបទ និងខ្លឹមសារនៃការបណ្តុះបណ្តាលយេនឌ័រលើ "គោលគំនិត និងទស្សនទាន WEE" មានប្រសិទ្ធភាពទាំងស្រុងក្នុងការនាំយកការផ្លាស់ប្តូរផ្នត់គំនិត និងអាកប្បកិរិយារបស់ស្ត្រី និងបុរសដែលជាក្រុមគោលដៅ។
- ដរាបណាប្រភេទណាមួយនៃសកម្មភាពបង្កើតប្រាក់ចំណូល និងអាជីវកម្មខ្នាតតូចរបស់ស្ត្រីនៅតាមជនបទត្រូវបានគាំទ្រយ៉ាងសមស្របជាមួយនឹងការ

ដោះស្រាយតម្រូវការរបស់ស្ត្រី និងបញ្ហាយេនឌ័រ។ WEE អាចត្រូវបានផ្សព្វផ្សាយក្នុងន័យទូលំទូលាយ ដែលអាចរួមចំណែកក្នុងការសម្រេចបានសមភាពយេនឌ័រ។

- ទោះបីជាថវិកានៅមានកម្រិតក៏ដោយ មន្ទីរពាក់ព័ន្ធជាច្រើនបានបង្ហាញថាមានលទ្ធភាពប្រើប្រាស់បទពិសោធន៍របស់ PGM-WEE តាមវិធីជាច្រើន។
- ការកសាងសមត្ថភាពគ្រប់ជ្រុងជ្រោយនៃមន្ទីរពាក់ព័ន្ធ គឺត្រូវបានទាមទារយ៉ាងខ្លាំងសម្រាប់ការលើកកម្ពស់ការបញ្ជ្រាបនៅថ្នាក់ខេត្ត។

៣.៥. សកម្មភាព ឬជំនួយបន្ថែម ចាំបាច់ក្នុងការឆ្លើយតបទៅនឹងកូវីដ-១៩

ដោយគិតគូរពីផលប៉ះពាល់នៃកូវីដ-១៩ ទៅលើសកម្មភាពសេដ្ឋកិច្ច ជាពិសេសក្នុងវិស័យទេសចរណ៍ក្នុងខេត្តគោលដៅ គឺខេត្តសៀមរាប និងខេត្តកំពង់ធំ គម្រោងបានស្នើ និងអនុវត្តសកម្មភាពបន្ថែមចំនួន៣ ដូចខាងក្រោម៖

(១). ការស្ទង់មតិអំពីស្ត្រីក្នុងវិស័យទេសចរណ៍ដែលរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩ ការស្ទង់មតិនេះ គឺដើម្បីប្រមូលទិន្នន័យអំពីផលប៉ះពាល់របស់កូវីដ-១៩ ទៅលើស្ត្រីដែលធ្វើការក្នុងវិស័យទេសចរណ៍ និងដើម្បីជួយគាំទ្រដល់ក្រសួង/មន្ទីរ ម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលដើម្បីស្វែងយល់អំពីតម្រូវការ និងត្រៀមរៀបចំកិច្ចអន្តរាគមន៍ចាំបាច់។ លទ្ធផលនៃការស្ទង់មតិត្រូវបានចែករំលែកជាមួយក្រសួង និងមន្ទីរពាក់ព័ន្ធក្នុងខេត្តសៀមរាប និងខេត្តកំពង់ធំ។

(២). សិក្ខាសាលាស្តីពីការគ្រប់គ្រងអនាម័យ (ពិសេសសម្រាប់ស្ត្រី) ក្នុងវិស័យទេសចរណ៍ សិក្ខាសាលានេះមានគោលបំណងកសាងចំណេះដឹង និងការយល់ដឹងអំពីការគ្រប់គ្រងអនាម័យក្នុងវិស័យទេសចរណ៍តាម រយៈការផ្តល់នូវវិធីសាស្ត្រអនុវត្តជាក់ស្តែងពាក់ព័ន្ធនឹងការគ្រប់គ្រងអនាម័យ ការតាមដានត្រួតពិនិត្យ និងការបញ្ជាក់ទទួលស្គាល់ បន្ទាប់ពីបានចូលរួមសិក្ខាសាលាក្រោមកិច្ចសហការរវាង MOWA និង MOT។ សិក្ខាសាលានេះធ្វើឡើងដោយជួបផ្ទាល់ និងតាមប្រព័ន្ធអនឡាញ ដើម្បីផ្សព្វផ្សាយការអនុវត្តអនាម័យត្រឹមត្រូវដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ (ជាពិសេសស្ត្រី) ដែលធ្វើការក្នុងវិស័យទេសចរណ៍។

(៣). គាំទ្រដល់ការផ្សព្វផ្សាយទេសចរណ៍ ផ្តោតលើស្ត្រីសកម្មក្នុងវិស័យទេសចរណ៍សកម្មភាពនេះបង្កើតជាវីដេអូខ្លីៗដោយផ្តោតលើស្ត្រីចូលរួមសកម្មក្នុងវិស័យទេសចរណ៍ ដើម្បីពង្រីកទំនាក់ទំនងសាធារណៈនៃ វិស័យទេសចរណ៍នៅកម្ពុជា ដើម្បីឱ្យភ្ញៀវទេសចរត្រឡប់ចូលមកវិញបានលឿនបន្ទាប់ពីជំងឺកូវីដ-១៩។ វីដេអូនេះ ផ្សព្វផ្សាយតាមបណ្តាញសង្គម (SNS) និងតាមរយៈការផ្សាយពាណិជ្ជកម្ម ដោយវិស័យឯកជនពាក់ព័ន្ធ។ វីដេអូនេះរៀបចំឡើងក្នុងគោលបំណងទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ ឱ្យចាប់អារម្មណ៍លើស្ត្រីដែលសកម្មក្នុងវិស័យទេសចរណ៍ និងដើម្បីរួមចំណែកជំរុញសកម្មភាពវិស័យទេសចរណ៍ក្នុងខេត្តសៀមរាប និងខេត្តកំពង់ធំឡើងវិញ។

IV. ការសម្រេចបាននូវគោលដៅរួមបន្ទាប់ពីការបញ្ចប់គម្រោង

៤.១. លទ្ធផលរំពឹងទុកក្នុងការសម្រេចបានគោលដៅរួម

| សូចនាករ | លទ្ធផលរំពឹងទុក |
|---|---|
| 1. កម្មវិធី និងគម្រោងដែលឆ្លើយតបនឹងយេនឌ័រ ត្រូវបានគ្រោង និងអនុវត្តដើម្បីលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ដោយផ្អែកលើគោលការណ៍ណែនាំអំពី WEE ដែល បានធ្វើបច្ចុប្បន្នភាព និងគោលការណ៍ណែនាំអំពីវិធីសាស្ត្រ PGM នៅក្នុងខេត្តគោលដៅ និងខេត្តមិនមែនគោលដៅ។ | មានការរំពឹងទុកខ្ពស់ថាគម្រោង និងសកម្មភាពដែលឆ្លើយតបនឹងយេនឌ័រនឹងត្រូវបានធ្វើផែនការ និងអនុវត្ត ឬយ៉ាងហោចណាស់ក៏មានទស្សនៈយេនឌ័រមួយចំនួនត្រូវបានបញ្ជ្រាប ទៅក្នុងការគ្រប់គ្រងវដ្តនៃគម្រោង ឬសកម្មភាពពាក់ព័ន្ធរបស់ WEE នៅក្នុងខេត្តគោលដៅ។ គិតត្រឹមខែតុលា ឆ្នាំ២០២២ បានរកឃើញថា មន្ទីរមួយចំនួនបានចាប់ផ្តើមបញ្ជ្រាបទស្សនៈទានយេនឌ័រ និង/ឬគោលគំនិតអំពី WEE ដែលបានរៀនសូត្រពីគម្រោង PGM-WEE |

| | |
|---|---|
| | ទៅក្នុងផែនការធម្មតារបស់ខ្លួន (ឧទាហរណ៍ផែនការប្រចាំឆ្នាំ និងផែនការវិនិយោគ ៣ឆ្នាំរំកិល) និងគម្រោង ឬសកម្មភាព ដែលមានស្រាប់ (ឧ. កសិពាណិជ្ជកម្ម ការបណ្តុះបណ្តាល វិជ្ជាជីវៈ ការណែនាំផ្នែករដ្ឋបាលសម្រាប់រោងចក្រកាត់ដេរ ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅថ្នាក់ភូមិ) ដោយប្រើប្រាស់ថវិកាកម្មវិធី។ ក្រៅពីនេះ ក៏មានការតម្រូវឱ្យខេត្តដែលមិនមែនគោលដៅ ទទួលបានជំនួយបច្ចេកទេសម្តងម្កាលពី MOWA និងក្រសួងពាក់ព័ន្ធផងដែរ។ |
| 2. កិច្ចប្រជុំ គ.ក.ស.ក ដើរតួនាទីជាវេទិកាមួយសម្រាប់ PDWA និងមន្ទីរពាក់ព័ន្ធដើម្បីពិភាក្សា និងត្រួតពិនិត្យកម្មវិធី និងគម្រោងដែលឆ្លើយតបនឹងយេនឌ័រ ដើម្បីលើកកម្ពស់ WEE នៅក្នុងខេត្តដែលមិនមែនជាគោលដៅ។ | ដោយសារតែទើបនឹងមានការសម្រេចក្នុងការរៀបចំមុខងារ និងរចនាសម្ព័ន្ធក្រុមការងារ WEE នៅក្នុងខេត្តគោលដៅនៅពេលបញ្ចប់គម្រោង យើងពិបាកនឹងរំពឹងទុកថាគេអាចបង្កើត និងធ្វើស្ថាប័នូបនីយកម្ម WEE បានល្អនៅក្នុងខេត្តដែលមិនមែនជាគោលដៅផ្សេងទៀតបានដែរឬទេ។ |
| 3. ក្រសួងដៃគូទាំងអស់ និង គ.ជ.អ.ប បានដាក់ បញ្ចូលអនុសាសន៍យ៉ាងតិច១ ទៅក្នុងគោលនយោបាយ / ផែនការតាមវិស័យរបស់ខ្លួន ឬគោលនយោបាយ / ផែនការយេនឌ័រ របស់ គ.ជ.អ.ប និងអនុវត្តកម្មវិធី និងគម្រោងដែលឆ្លើយតបនឹងយេនឌ័រដើម្បីលើកកម្ពស់ WEE នៅថ្នាក់ក្រោមជាតិ។ | ក្រសួងដៃគូទាំងអស់ បានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនក្នុងការបញ្ចូលអនុសាសន៍ និងគន្លឹះណែនាំពីគម្រោង PGM-WEE ទៅក្នុងគោលនយោបាយ ផែនការ និងគម្រោងរបស់ខ្លួន។ ខណៈពេលដែលប្រជុំពិភាក្សាទៅលើផែនការយុទ្ធសាស្ត្រសម្រាប់អនុវត្តគោលនយោបាយ ជាមួយនឹងក្រសួងកិច្ចការនារី គ.ជ.អ.ប ក៏បានទទួលស្គាល់ថា ឧបករណ៍ដែលគម្រោងបានបង្កើត និងមេរៀនបទពិសោធន៍ដែលទទួលបានគឺមានប្រសិទ្ធិភាពក្នុងការអនុវត្ត។ ប៉ុន្តែ វាអាស្រ័យជាធំទៅលើស្ថានភាពថវិការបស់រាជរដ្ឋាភិបាល និងលទ្ធភាពដែល MOWA អាចធ្វើការស្វែងរកការគទ្រតស៊ូមតិ និងសម្របសម្រួលប្រកបដោយប្រសិទ្ធភាពជាមួយMEF និងក្រសួងពាក់ព័ន្ធ ដើម្បីទទួលបានថវិកាចាំបាច់សម្រាប់អនុវត្ត។ MOWA ជាពិសេសនាយកដ្ឋានសមភាពយេនឌ័រ ចាំបាច់ត្រូវបន្តការស្វែងរកការគាំទ្រមតិ និងការសម្របសម្រួលជាបន្តបន្ទាប់។ |

៤.២. ផែនការប្រតិបត្តិការ និងរចនាសម្ព័ន្ធអនុវត្តការងាររបស់ភាគីកម្ពុជា ដើម្បីសម្រេចបាននូវគោលដៅរួម

| សូចនាករ | សកម្មភាពចាំបាច់ |
|---|---|
| 1- កម្មវិធី និងគម្រោងដែលឆ្លើយតបនឹងយេនឌ័រ ត្រូវបានគ្រោង និងអនុវត្តដើម្បីលើកកម្ពស់ WEE ដោយផ្អែកលើគោលការណ៍ណែនាំស្តីអំពី WEE ដែលបានធ្វើបច្ចុប្បន្នភាព និងគោលការណ៍ណែនាំអំពីវិធីសាស្ត្រ PGM នៅ ក្នុងខេត្តគោលដៅនិងខេត្តមិនមែនគោលដៅ។ | • បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសសម្រាប់ PDWA នៅក្នុងខេត្តមិនមែនគោលដៅ ដោយកែប្រែខ្លឹមសារនៃសិក្ខាសាលា PGM ដែលបច្ចុប្បន្នត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំដោយប្រើថវិកាតាមកម្មវិធី (PB) (២-៣ខេត្ត / ឆ្នាំ)។<br>• បញ្ជាក់អំពីការដាក់បញ្ចូលគោលគំនិត និងទស្សនយេនឌ័រ និង WEE |

| | |
|---|---|
| | ទៅក្នុងផែនការប្រចាំឆ្នាំរបស់ PDWA។<br>• ការស្វែងរកការគាំទ្រមតិ និងសម្របសម្រួលជាមួយមន្ទីរ ដើម្បីបញ្ចូលគោលគំនិត និងទស្សនទានយេនឌ័រ និង WEE ទៅក្នុងផែនការ ឬគម្រោង។<br>• តាមដានស្ថានភាពនៃការបញ្ជ្រាបយេនឌ័រនៅក្នុងផែនការប្រចាំឆ្នាំរបស់មន្ទីរផ្សេងៗតាមរយៈសេចក្តី រាយការណ៍ទៀងទាត់ពី PDWA។ |
| 2- កិច្ចប្រជុំ គ.ក.ស.ក ដើរតួនាទីជាវេទិកាមួយសម្រាប់ PDWA និងមន្ទីរ ដើម្បីពិភាក្សា និងត្រួតពិនិត្យកម្មវិធី និងគម្រោងដែលឆ្លើយតបនឹងយេនឌ័រ ដើម្បីលើកកម្ពស់ WEE នៅក្នុងខេត្តដែលមិនមែនជាគោលដៅ។ | • យោងទៅតាមបទពិសោធន៍របស់ខេត្តគោលដៅក្នុងការរៀបចំមុខងាររបស់ក្រុមការងារ WEE ដែលជាវេទិកាសម្រាប់បញ្ជ្រាបយេនឌ័រនៅថ្នាក់ខេត្ត MOWA ត្រូវបានរំពឹងថានឹងបន្តតាមដានវឌ្ឍនភាព និងសម្របសម្រួលការពិភាក្សាអំពីការរៀបចំជាផ្លូវការនូវយន្តការសមស្របសម្រាប់បញ្ជ្រាបយេនឌ័រនៅថ្នាក់ខេត្ត ដោយសម្របសម្រួលជាមួយក្រសួងមហាផ្ទៃ ហើយចាប់ផ្តើមបង្កើតយន្តការនៅខេត្តមិនមែនគោលដៅ។ |
| 3- ក្រសួងពាក់ព័ន្ធទាំងអស់ និង គ.ជ.អ.ប បានដាក់បញ្ចូលអនុសាសន៍យ៉ាងតិច១ ទៅក្នុងគោលនយោបាយ / ផែនការតាមវិស័យរបស់ខ្លួន ឬគោលនយោបាយ / ផែនការយេនឌ័រ របស់ គ.ជ.អ.ប និងអនុវត្តកម្មវិធី និងគម្រោងដែលឆ្លើយតបនឹងយេនឌ័រដើម្បីលើកកម្ពស់ WEE នៅថ្នាក់ក្រោមជាតិ។ | • តាមដានស្ថានភាពនៃការបញ្ជ្រាបយេនឌ័រនៅក្នុង GMAP ឬផែនការតាមវិស័យ តាមរយៈកិច្ចប្រជុំ GMAG មួយដងក្នុងមួយឆ្នាំយ៉ាងតិច។<br>• យោងទៅលើមេរៀន និងឧបករណ៍ដែលទទួលបានពីគម្រោង គ.ជ.អ.ប និងក្រសួងកិច្ចការនារីបានពិភាក្សាគ្នាស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រ និងការអនុវត្តគោលនយោបាយយេនឌ័ររបស់ គ.ជ.អ.ប។ |

៤.៣. អនុសាសន៍សម្រាប់ភាគីកម្ពុជា

- ក្រសួងកិច្ចការនារី ត្រូវបានរំពឹងថានឹងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់មន្ទីរកិច្ចការនារីទាំងនៅក្នុងខេត្តគោលដៅ និងខេត្តមិនមែនគោលដៅ ដើម្បីបង្កើនការបញ្ជ្រាបយេនឌ័រនៅក្នុងសកម្មភាពទាក់ទងនឹង WEE នៅថ្នាក់ខេត្ត។ គួរធ្វើការកែប្រែខ្លឹមសារនៃសិក្ខាសាលា PGM ដោយបញ្ចូលខ្លឹមសារនៃគោលការណ៍ណែនាំអំពី WEE ពីព្រោះមានខ្វះថវិកាចាំបាច់សម្រាប់កិច្ចការនេះជារៀងរាល់ឆ្នាំ។
- វឌ្ឍនភាពនៃការផ្សព្វផ្សាយ WEE នៅថ្នាក់ខេត្ត គឺតម្រូវឱ្យចែករំលែកនៅក្នុងកិច្ចប្រជុំ TWG-G WEE ដែលត្រូវបានគេសន្មត់ថានឹងធ្វើឡើងជាទៀងទាត់។
- ដើម្បីធានាបាននូវផែនការ និងការអនុវត្តសកម្មភាព WEE ដែលឆ្លើយតបទៅនឹងយេនឌ័រនៅថ្នាក់ខេត្តក្រសួងកិច្ចការនារីចាំបាច់គួរពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MOEF) ដើម្បីស្នើសុំថវិកាចាំបាច់ ឬចរចាជាមួយដៃគូអភិវឌ្ឍន៍ផ្សេងទៀតដើម្បីទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុបន្ថែមសម្រាប់កិច្ចការលើកកម្ពស់ WEE។
